ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសិក្សាធិការ

# ទស្សន៍ខេមរភាសា

កុមារដ្ឋាន

នាមលោកអ្នកតែង: ម៉ាធីត្យុង៍, ឈឹម-សុទ្ធ, ចិម-ប៉ែង

បោះពុម្ពលើកទី ៤

រោងពុម្ព ហាង្ស-រី

លេខ ៧៥_៧៧_៧៩ វិថីអូហ៊ីយេរ ភ្នំពេញ.

ព.ស. ២៤៩៦ គ.ស. ១៩៥៣

តម្លៃ [illegible]

CA5

សៀវភៅនេះ ក្រសួងសិក្សាធិការបានប្រគល់ឲ្យ គណៈកម្មការ
ពិនិត្យមើល និងរៀបរៀងឡើងវិញក្នុង គ. ស. ១៩៥១ មាន :

លោកអ្នកឧកញ៉ា អ៊ុំ - ឈាង - ស៊ុន ប្រធានក្រុមប្រឹក្សាព្រះរាជ-
អាណាចក្រ ជាអធិបតី ។

លោក ឈឹម - សុទ្ធ, អ៊ុំ - ឈុំ, ស៊ិន - ស៊ុយ, ស្រី - ស៊ុំ, ព្រំ - មុត,
ស្វាយ - អ៊ុន, ត្រឹង - មុល ជាសមាជិក ៗ

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសិក្សាធិការ

# បឋម

# វិជ្ជាខេមរភាសា

## កុមារដ្ឋាន

នាមលោកអ្នកតែង: ម៉ាធីតូ៍ ឈឹម-សុទ្ធ, ចិម-ប៉ែន

បោះពុម្ពលើកទី ៤

IMPRIMERIE HENRY

គ. ស. ១៩៥៣

# មេរៀនទី ១

## ស្រះ

ក្នុងភាសាខ្មែរមានស្រះដើមពេញតួតែមួយ (ស្រះនិស្សិត) គឺស្រះ *អ* ។ ប៉ុន្តែស្រះ *អ* គេះ បង្កើតបានជាស្រះច្រើនទៀត (ស្រះនិស្ស័យ) ដោយផ្សំនឹងសញ្ញាផ្សេង ៗ ហៅថា *សញ្ញា ស្រះ* ដាក់ពីលើ ឬពីមុខ ពីក្រោយ ពីក្រោមស្រះដើម *អ* ដើម្បីឲ្យប្រែសំដីដើម ។ ឯសំដីដែលប្រែនេះក៏ផ្លាស់ប្តូរទៀតតាមព្យញ្ជនៈ *អឃោសៈ* (ព្យញ្ជនៈឮស្រាលដូចជា *ក ខ ច ឆ ដ* ។ល។) ឬពួក *ឃោសៈ* ឮធ្ងន់ដូចជា *គ ឃ ង ជ ឈ ញ* ។ល។)

| ឮស្រះបំបែកសំរាប់ពួកព្យញ្ជនៈ *អឃោសៈ* |
|---|

# អ â

អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ

អេ អែ អៃ អោ អៅ អុំ អំ អាំ អះ ៗ អេះ អុះ ៗ

# អារម្ភកថា

សៀវភៅនេះ យើងបានរៀបរៀងតាមលំដាប់រៀនឆាប់ សំរាប់ថ្នាក់កុមារដ្ឋាន ។

ដំបូងគឺរៀនខ្យល់ស្រៈទាំងពីរពួក រួចទើបផ្សំនឹងព្យញ្ជនៈ ឯព្យញ្ជនៈនេះទៀត គឺដាក់រៀងហូរហែតាមលំដាប់ជាវគ្គៈ ៗ កាលផ្សំព្យញ្ជនៈទីមួយៗ នឹងស្រៈ តែងតែមានការហាត់នៅខាងក្រោមផង សំរាប់ហ្វឹកហ្វឺនសិស្សឲ្យមើលថា ឬឲ្យសរសេរតាមថា ការហាត់នេះដំរៀបឲ្យនៅជិតគ្នាតាមភាពអក្សរដែលសរសេរស្រដៀងគ្នា ឬតាមសំដីប្រហែលគ្នា ហើយមានទាំងពាក្យរាយ ឬពាក្យចងជាឃ្លាងាយ ៗ នៅខាងក្រោមទៀតផង ។

មួយទៀត ដើម្បីនឹងចៀសវាងការហាត់ចោលឥតប្រយោជន៍ យើងឲ្យរៀនជើងព្យញ្ជនៈ លុះតែត្រូវការប្រើភ្លាមក្នុងមេរៀនផ្ញើជើង ក្រោយមេរៀនប្រកបនានា ៗ មេរៀនទីមួយ ៗ សឹងមានក្បួនពន្យល់ផងដាក់នៅក្នុងខណ្ឌបួនជ្រុងសម្រាប់គ្រូ ។

ភាគទីពីរ ជារឿងមើលហូរហែគ្មានពាក្យណាពិបាកទេ ចៀសវាងពាក្យបាលី ឬសំស្ក្រឹតណាដែលពុំសូវមានប្រើក្នុងភាសាធម្មតា ។

នៅចុងបំផុតមានដាក់ថែមមេរៀន សន្តានពាក្យដែលកើតចេញពីគ្នាផង ។

# មេរៀនទី ១

## ស្រៈ

ក្នុងភាសាខ្មែរមានស្រៈដើមពេញតួតែមួយ (ស្រៈនិស្សិត) គឺស្រៈ *អ* ។ ប៉ុន្តែស្រៈ *អ* នេះ បង្កើតបានជាស្រៈច្រើនទៀត (ស្រៈនិស្ស័យ) ដោយផ្សំនឹងសញ្ញាផ្សេង ៗ ហៅថា *សញ្ញា ស្រៈ* ដាក់ពីលើ ឬពីមុខ ពីក្រោយ ពីក្រោមស្រៈដើម *អ* ដើម្បីឲ្យប្រែសំដីដើម ។ ឯសំដីដែលប្រែនេះ ក៏ផ្លាស់ប្តូរទៀតតាមព្យញ្ជនៈ *អ ឃោសៈ* (ព្យញ្ជនៈខ្យល់ស្រាលដូចជា *ក ខ ប ឆ ជ* ។ល។) ឬពួក *ឃោសៈ* ខ្យល់ធ្ងន់ដូចជា *គ ឃ ង ជ ឈ ញ* ។ល។)

| ខ្យល់ស្រះបំបែកសំរាប់ពួកព្យញ្ជនៈ *អឃោសៈ* |
|---|

# អ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ

អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ

អេ អែ អៃ អោ អៅ អុំ អំ អាំ អះ ។ អេះ អុះ ។

# ការហាត់

ឲ្យមើលថា ឬឲ្យសរសេរតាមសូត្រ

អ អំ អុំ អុ ។ អា អាំ អោ អៅ ។ អូ អួ ។
អិ អី អឹ អឺ អើ អឿ អៀ ។ អេ អែ អៃ ។ អះ អេះ
អុះ ។ អាអំអេះអាអាំ ។

ចម្លង អក្សរផ្ចង់

ឲ្យសរសេរស្រះ អ បំបែករៀងតាមលំដាប់ខាងលើ

*របៀបបង្រៀន* — ក្នុងការបំបែកស្រះនេះ ត្រូវឲ្យរៀនចាំស្គាល់មែនទែន ត្រូវឲ្យថាសំដីឲ្យច្បាស់លាស់ ហើយត្រូវហ្វឹកហ្វឺនឲ្យហាត់ថាសំដីផ្សំនឹងព្យញ្ជនៈខ្លះផង ឧបមាដូចក្នុងស្រះ *អើ* ត្រូវឲ្យហាត់ថា *អើ ដើ បើ ហើ ។ល។*

ហាមដាច់មិនឲ្យមើលថាបង្ហួសបែបធ្វើបទ ។

# មេរៀនទី ២

ឲ្យល់ស្រៈបំបែកសម្រាប់ពួកព្យញ្ជនៈ ឃោសៈ

# អ៊

អ៊ អ៊ា អ៊ិ អ៊ី អ៊ឹ អ៊ឺ អ៊ុ អ៊ូ អ៊ួ អ៊ើ អ៊ឿ អ៊ៀ
អ៊េ អ៊ែ អ៊ៃ អ៊ោ អ៊ៅ អ៊ុំ អ៊ំ អ៊ាំ អ៊ះ ៗ អ៊េះ អ៊ិះ
អ៊ុះ ៗ

## ការហាត់

ឲ្យមើលថា ឬឲ្យសរសេរតាមសូត្រ

អ៊ អ៊ឹ អ៊ុ អ៊ុំ ៗ អ៊ា អ៊ៀ អ៊ាំ អ៊ោ អ៊ៅ ៗ អ៊ួ អ៊ូ ៗ
អ៊ិ អ៊ឹ អ៊ី អ៊ឺ អ៊ើ អ៊ឿ ៗ អ៊េ អ៊ែ អ៊ៃ ៗ អ៊ះ អ៊ិះ
អ៊ុះ អ៊េះ ៗ

ចម្លង – អក្សរផ្ចង់

ឲ្យសរសេរស្រះ អ៊ បំបែករៀងតាមលំដាប់ខាងលើ

របៀបបង្រៀន – ធ្វើដូចកាលបង្រៀនស្រះ អ ហើយឲ្យថាឲ្យត្រូវសំដីនៃស្រះ អ៊ា នឹង អ៊ៀ ដូចក្នុងពាក្យ ទាន មាន កន ទៀន មៀន រៀន ។ល។ ហើយនឹងស្រះ អុំ អំ អាំ (អុំ ដូចក្នុងពាក្យ ជុំ រុំ ឃុំ ។ អំ ដូចក្នុងពាក្យ នំ យំ ធំ ។ អាំ ដូចក្នុងពាក្យ នាំ មាំ ភាំ) ។

*

* *

## ព្យញ្ជនៈផ្សំនឹងស្រះ

ព្យញ្ជនៈរៀនចែកជាលំដាប់ ៥ វគ្គ ហើយក្នុងមួយវគ្គៗ មាន តួព្យញ្ជនៈ ៥ បង្ហើយនឹងព្យញ្ជនៈសំដីដោយក្នុងប្រមុះ (នាសិកជៈ) ។ ឯ ព្យញ្ជនៈពុំពេញទីក្រោយពីវគ្គទី ៥ ទៅ ជាអក្សរក្រៅវគ្គ (សេសវគ្គ) ។

# មេរៀនទី ៣

ព្យញ្ជនៈ ក ផ្សំនឹងស្រៈ(បំបែក)

# ក

ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ

កេ កែ កៃ កោ កៅ កុំ កំ កាំ កះ ។ កេះ កុះ ។

## ការហាត់

ឲ្យមើលចា ឬឲ្យសរសេរតាមសូត្រ

កិ កើ កឺ កែ កៃ កេ ។ កា កាំ កៅ កោ ។

កូ កួ ។ កឿ កៀ ។ កុ កុំ កំ ។ កកេ ។ កុះ កុំ ។

កៅអី ។ អាកែកេះអាកោ ។

*ចម្លង–អក្សរផ្ចង់*

ឲ្យសរសេរ ក បំបែករៀងតាមលំដាប់ខាងលើ

## មេរៀនទី ៤

# គ

គ គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ
គែ គៃ គោ គៅ គុំ គំ គាំ គះ ៗ គេះ គិះ គុះ ៗ

### ការហាត់

ឲ្យមើលថា ឬឲ្យសរសេរតាមសូត្រ

គ គោ គូ គៅ ៗ គឺ គើ គឿ គូ គួ គៀ គោ ៗ
កី គែ កែ ៗ គេ កេ
គែ កៃ ៗ គុំ គំ គាំ គុ ៗ
គគី(រ) ៗ គេគុំអាគាំ ៗ
គោអាកៅ ៗ



គោ

ចម្ង-អក្សរផ្ចង់

ឲ្យសរសេរ គ បំបែករៀងតាមលំដាប់ខាងលើ

មេរៀនទី ៥

K Kh K Kh Ngo

# ក ខ គ ឃ ង

ឱ្យហាត់រាប់ថា ហើយនឹងធ្វើតួព្យញ្ជនៈទាំង៥នេះឱ្យត្រូវសិន

ខ ខា ខិ ខី ខឹ ខឺ ខុ ខូ ខួ ខើ ខឿ ខៀ

ខេ ខែ ខៃ ខោ ខៅ ខុំ ខំ ខាំ ខះ ៗ ខេះ ខុះ ៗ

ឃ ឃា ឃិ ឃី ឃឹ ឃឺ ឃុ ឃូ ឃួ ឃើ

ឃឿ ឃៀ ឃេ ឃែ ឃៃ ឃោ ឃៅ ឃុំ ឃំ ឃាំ

ឃះ ៗ ឃេះ ឃិះ ឃុះ ៗ

ង ងា ងិ ងី ងឹ ងឺ ងុ ងូ ងួ ងើ ងឿ ងៀ

ងេ ងែ ងៃ ងោ ងៅ ងុំ ងំ ងាំ ងះ ៗ ងេះ ងិះ ងុះ ៗ

# ការហាត់

ឲ្យមើលថា ឬឲ្យសរសេរតាមសូត្រ

កា កោ កៅ កាំ ។ ខិ ខី ខៀ ខើ ។ គា គៀ
គឺ ។ ឃូ ឃុ ឃេ ឃៃ ។ ងៃ ងំ ងុំ ងះ ។ កេះ
កុះ ។ គិះ គុះ គេះ ។ ក គ ក្ង គោ គី គែ កៃ ។
គឹ គឿ គើ គ្ឃ កេ គេ
កែ គែ គំ គុំ គាំ ។
ឃុំគឺ(រ) ។ ងើង ។ ខោ
អាឃី ។ អាកែខាំអាកៅ ។
អាគាំខំកៃខែ ។



ចម្ងង — អក្សរផ្ចង់
ឲ្យសរសេរព្យញ្ជនៈ បំបែកខាងលើ

# សាឡើងវិញ

៣

## ក ខ គ ឃ ង

ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ
កេ កែ កៃ កោ កៅ កុំ កំ កាំ កះ ៗ កេះ កុះ ៗ

ខ ខា ខិ ខី ខឹ ខឺ ខុ ខូ ខួ ខើ ខឿ ខៀ
ខេ ខែ ខៃ ខោ ខៅ ខុំ ខំ ខាំ ខះ ៗ ខេះ ខុះ ៗ

គ គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ
គេ គែ គៃ គោ គៅ គុំ គំ គាំ គះ ៗ គេះ គិះ
គុះ ៗ

ឃ ឃា ឃិ ឃី ឃឹ ឃឺ ឃុ ឃូ ឃួ ឃើ
ឃឿ ឃៀ ឃេ ឃែ ឃៃ ឃោ ឃៅ ឃុំ ឃំ ឃាំ
ឃះ ៗ ឃេះ ឃិះ ឃុះ ៗ

ង ងា ងិ ងី ងឹ ងឺ ងុ ងូ ងួ ងើ ងឿ ងៀ
ងេ ងែ ងៃ ងោ ងៅ ងុំ ងំ ងាំ ងះ ៗ ងេះ ងិះ ងុះ ៗ

អី អែ អៃ ។ អឺ អើ អ្ឫ អឿ អៀ ។ អោ អៃ អ
អៅ អូ ។ កី កែ កៃ ។ គឺ គើ គ្ឫ គឿ គៀ ។ គេ
គៃ ។ គ គៅ គូ គួ ។ ឃី ឃែ ឃៃ ។ ឃឺ ឃើ ឃ្ឫ
ឃឿ ឃៀ ។ ឃោ ឃៃ ឃ ឃៅ ឃូ ឃួ ។ អុំ អំ
អាំ ។ គុំ គំ គាំ ។ ឃុំ ឃំ ឃាំ ។ ង៉ុំ ង៉ំ ង៉ាំ ។
អាកែកោរអាគាំ ។ រាអំខំកេះអាអុំ ។ គេឃុំគោអាឃើ ។
អាគៅងេងើ ៗ

# មេរៀនទី ៦

# ចឆជឈញ

ឲ្យហាត់រាប់ថា ហើយនឹងធ្វើតួព្យញ្ជនៈទាំង ៥ នេះឲ្យត្រូវសិន ។

ច ចា ចិ ចី ចឹ ចឺ ចុ ចូ ចួ ចើ ចឿ ចៀ
ចេ ចែ ចៃ ចោ ចៅ ចុំ ចំ ចាំ ចះ ។ ចេះ ចុះ ។

ឆ ឆា ឆិ ឆី ឆឹ ឆឺ ឆុ ឆូ ឆួ ឆើ ឆឿ ឆៀ
ឆេ ឆែ ឆៃ ឆោ ឆៅ ឆុំ ឆំ ឆាំ ឆះ ។ ឆេះ ឆុះ ។

ជ ជា ជិ ជី ជឹ ជឺ ជុ ជូ ជួ ជើ ជឿ ជៀ
ជេ ជែ ជៃ ជោ ជៅ ជុំ ជំ ជាំ. ជះ ។ ជេះ ជិះ ជុះ ។

ឈ ឈា ឈិ ឈី ឈឹ ឈឺ ឈុ ឈូ ឈួ
ឈើ ឈឿ ឈៀ ឈេ ឈែ ឈៃ ឈោ ឈៅ
ឈុំ ឈំ ឈាំ ឈះ ។ ឈេះ ឈិះ ឈុះ ។

ញ ញា ញិ ញី ញឹ ញឺ ញុ ញូ ញួ ញើ ញឿ ញៀ ញេ
ញែ ញៃ ញោ ញៅ ញុំ ញំ ញាំ ញ៉ះ ។ ញេះ ញិះ ញុះ ។

## ការហាត់

ឲ្យមើលអាន ឬឲ្យសរសេរតាមថា

ពៅ ពោ ពាំ ពា ។ ធើ ធី ធិ ធឿ ធៀ ។ ប៉េះ ប៉ុះ ។ ធុ ធុំ ធំ ។ ប៊ី បៃ ។ ជៅ ជាំ ជា ជោ ។ ជិះ ជុះ ។ ឈី ឈើ ឈូ ឈួ ឈុំ ។ ញី ញេ ញាំ ញើ ។ ពៅឈុំ ឈឺ ។ កុំជឿអាធុំ ។ ខោពៅ ធាំផេះ ។ បៃខាំអាធេ ។ ពៅជុំ ជិះគោញី ។ ពៅជួបេះខៃឈើ ។ កៅអីឈើ ។ ពៅជៃធាធៅអាជា ។



៤០

ចម្លង — អក្សរផ្ចង់

ឲ្យសរសេរព្យញ្ជនៈបំបែករៀងតាមលំដាប់ខាងលើ

## មេរៀនទី ៧

# ដ ដ្ឋ ឌ ឍ ណ

ដ្ឋ=ឋ

| |
|---|
| ឲ្យហាត់ភប់ថា ហើយនឹងធ្វើតួព្យញ្ជនៈទាំងនេះឲ្យត្រូវសិន ។ |
| ឯព្យញ្ជនៈបីតួ ដ្ឋ ឌ ឍ ស្ទើរតែមិនត្រូវការទេ ។ |

ដ ដា  ដិ ដី ដឹ ដឺ  ដុ ដូ ដួ  ដើ ដឿ ដៀ

ដេ ដែ ដៃ  ដោ ដៅ  ដុំ ដំ ដាំ  ដះ ។ ដេះ ដុះ ។

ណ ណា  ណិ ណី ណឹ ណឺ  ណុ ណូ ណួ

ណើ ណឿ ណៀ  ណេ ណែ ណៃ  ណោ ណៅ

ណុំ ណំ ណាំ  ណះ ។ ណោះ ណុះ ។

# ការហាត់

ឲ្យមើលហា ឬឲ្យសរសេរតាមសូត្រ

ឌា ឌាំ ឌោ ឌៅ ។ ឌី ឌៃ ។ ឌែ ឌេ ឌួ ឌើ
ឌៀ ឌឿ ។ ឌុ ឌុំ ឌិ ។ ណា
ណៅ ណោ ណាំ ។ ណិ ណឹ
ណើ ។ ណួ ណូ ។ ឌុំឌី ។
ឈើឌុះ ។ បំណុះ ។ បំណោះ ។
បំណើ ។ បំណាំ ។ ចៅឌាឈឺ
ឌៃ ។ ចៅណើឌាំឌំណាំ ។



ដៃ

ចម្លង—អក្សរផ្ចង់
ឲ្យសរសេរបំបែកព្យញ្ជនៈខាងលើ

## មេរៀនទី ៨

# ត ប ទ ធ ន

ឲ្យហាត់រាប់ភោ ហើយនឹងធ្វើរូបព្យញ្ជនៈ ទាំង ៥ នេះឲ្យត្រូវសិន

ត តា តិ តី តឹ តឺ តុ តូ តួ តើ តឿ តៀ
តេ តែ តៃ តោ តៅ តុំ តំ តាំ តះ ។ តេះ តុះ ។
ប បា បិ បី បឹ បឺ បុ បូ បួ បើ បឿ បៀ
បេ បែ បៃ បោ បៅ បុំ បំ បាំ បះ ។ បេះ បុះ ។
ទ ទា ទិ ទី ទឹ ទឺ ទុ ទូ ទួ ទើ ទឿ ទៀ
ទេ ទែ ទៃ ទោ ទៅ ទុំ ទំ ទាំ ទះ ។ ទេះ ទិះ ទុះ ។
ធ ធា ធិ ធី ធឹ ធឺ ធុ ធូ ធួ ធើ ធឿ ធៀ
ធេ ធែ ធៃ ធោ ធៅ ធុំ ធំ ធាំ ធះ ។ ធេះ ធិះ ធុះ ។
ន នា និ នី នឹ នឺ នុ នូ នួ នើ នឿ នៀ
នេ នែ នៃ នោ នៅ នុំ នំ នាំ នះ ។ នេះ និះ នុះ ។

# ការហាត់

ឲ្យមើលតា ឬឲ្យសរសេរតាមសូត្រ

ត តាំ តោ តៅ ។ តៃ តី ទៃ ។ តេ តែ ទេ
ទៃ ។ តុ តុំ តំ ។ ទុ ទុំ ទំ ទាំ ។ បិ បើ ។ ធ ធោ
បូ ធូ ធី ធើ ។ ធួ ធឿ ធៀ ។ ធុំ ធំ ។ បៃ បឺ
ធៃ ធំ ។ ឈាំ នាំ នៅ នោ ។
នឿ នេុ នៃ ។ នុ នុំ នំ ។
ទទា ។ ទទេ ។ ទីទៃ ។ តាទុំ
ទះដៃ ។ បោបៅនាំអាធូទៅណា ។
បីទៀនៅទីនេះ ។ ធូនេះធំ ។
អាតុំធំនុំអី ។



តែ

ចម្លង—អក្សរផ្ចង់

ឲ្យសរសេរព្យញ្ជនៈបំបែករៀងតាមលំដាប់ខាងលើ

## សាឡើងវិញ

*កខគឃង ចឆជឈញ ដឋឌឍណ តថទធន*

ប៊ី ប៉ៃ ង៉ៃ ។ ជ៊ី ឆ៉ៃ ឈៃ ។ ឈឺ ឈើ ឈូ ឈឿ ឈៀ ។ ជា ជៀ ។ ញឺ ញើ ។ ញា ញៀ ញាំ ញៅ ញោ ។ ដី ដៃ ដូ ដួ ដាំ ដុំ ដិ ។ តី តៃ ទៃ ។ បី បៃ ផៃ ។ ផី ផើ ផួ ផឿ ផៀ ផុំ ផំ ផាំ ។ ទា ទៀ ។ ទីទៃ ។ នា នាំ នោ នៅ ។ នៃ ន៉ៃ នេះ នុះ ។ ផេះ បេះ បុះ បំណេះ បំណុះ ។ អាគាំទៅណា ។ តាដៃឈឺដៃ ។ តុនេះធំ ។ បៅធុំបាទេ ។ គេដាំដំណាំ ។ បៅបាំនៅទីនេះ ។ ទូនេះនៅទទេ ។ តាផៃខៃឈើ ។ អាឈុំដៃដើ ។ កុំជឿអាជុំ ។ តាទុំជិះគោ ។ អាប៊ូទះដៃ ។

មេរៀនទី ៩

# ប ផ ព ភ ម

ឲ្យហាត់រាប់ថា ហើយនឹងធ្វើតួព្យញ្ជនៈទាំង ៥ នេះឲ្យត្រូវសិន

ប បា  បិ បី បឹ បឺ  បុ បូ បួ បើ  បឿ បៀ

បេ បែ បៃ  បោ បៅ  បុំ បំ បាំ បះ ។ បេះ បុះ ។

ផ ផា  ផិ ផី ផឹ ផឺ  ផុ ផូ ផួ  ផើ ផឿ ផៀ

ផេ ផែ ផៃ  ផោ ផៅ  ផុំ ផំ ផាំ ផះ ។ ផេះ ផុះ ។

ព ពា  ពិ ពី ពឹ ពឺ  ពុ ពូ ពួ  ពើ ពឿ ពៀ

ពេ ពែ ពៃ  ពោ ពៅ  ពុំ ពំ ពាំ ពះ ។ ពេះ ពិះ ពុះ ។

ភ ភា  ភិ ភី ភឹ ភឺ

ភុ ភូ ភួ  ភើ ភឿ ភៀ ភេ

ភែ ភៃ  ភោ ភៅ  ភុំ ភំ

ភាំ ភះ ។ ភេះ ភិះ ភុះ ។



ម មា មិ មី មឹ មឺ មុ មូ មួ មើ មឿ មៀ



មេ មែ មៃ មោ មៅ មុំ មំ មាំ

មះ ៗ មេះ មិះ មុះ ៗ

មេអំបៅ

## ការហាត់

ឲ្យមើលថា ឬឲ្យសរសេរតាមសូត្រ

បី បើ បឿ បៀ ៗ បៅ បំបៅ ដំបៅ ៗ បៃ បុះ
បេះ ៗ ផេះ ផុះ ៗ ផៅ ផា ផោ ផាំ ៗ ផៃ ផេ ផែ
ផើ ៗ ពៀ ពា ៗ ពៅពញា ៗ ពុំ ពំ ពាំ ៗ ពពែ ៗ
ពី ពើ ពួ ពឿ ពៀ ៗ ផី ផៃ ភៃ ៗ បំភៃ ភ ភោ ៗ
ភូ ផូ ៗ



បៀ

. មី មើ មូ មឿ ។ មៀ មា ។ បា បោ បៅ បាំ ។
ពា ពោ ពៅ ហាំ ។ ចេអំបោ ។ អំពៅ ។ ពូបៅ ។
មេឃុំ ។ ទំពា ។ បំពេ ។ បៅផៅពូកែគុះឈើ ។ បៅ
ភុំឈើដំបៅ ។ បៅពញាមេឃុំគគីរ ។ អាមីបំភៃពពៃញី ។
បៅភីនៅបៅ ។ ពូផូដាំអំពៅ ។

*ចម្លង - អក្សរផ្ចង់*
ឲ្យសរសេរបំបែកព្យញ្ជនៈខាងលើ

*សេចក្ដីបំណាំ* — ព្យញ្ជនៈ ប ផ្សំនឹងស្រៈ "ទាញយារ" ដូចជា ា ោ ៅ ាំ
ទ ១ — ត្រូវទាញស្រៈពីព្រះកេសដើម ជាការចៀសវាងកុំឲ្យថាជាអក្សរ ហ ដែលនឹងឃើញទៅខាងមុខ ។ ទ ២ — ត្រូវដាក់បន្ទាត់ត្រង់ចុះទៅក្រោមបន្តិចពីខាងក្រោម ដើម្បីកុំឲ្យច្រឡំនឹងអក្សរ ប ។

៦៣
667

ព្រលឹងខ្មែរ

## មេរៀនទី ១០

# យ រ ល វ

ឲ្យហាត់រាប់ថា ហើយនឹងធ្វើតួព្យញ្ជនៈទាំង ៤ នេះឲ្យត្រូវសិន

យ យា យិ យី យឹ យឺ យុ យូ យួ យើ យឿ
យៀ យេ យែ យៃ យោ យៅ យុំ យំ យាំ យះ ។
យេះ យិះ យុះ ។

រ រា រិ រី រឹ រឺ រុ រូ រួ រើ រឿ រៀ រេ រែ រៃ
រោ រៅ រុំ រំ រាំ រះ ។ រេះ រិះ រុះ ។

ល លា លិ លី លឹ លឺ លុ លូ លួ លើ
លឿ លៀ លេ លែ លៃ លោ លៅ លុំ លំ លាំ
លះ ។ លេះ លិះ លុះ ។

វ វា វិ វី វឹ វឺ វុ វូ វួ វើ វឿ វៀ វេ វែ
វៃ វោ វៅ វុំ វំ វាំ វះ ។ វេះ វិះ វុះ ។

# ការបាត់

ឲ្យមើលថា ឬសរសេរតាមសូត្រ

យៀ យា យាំ យោ យៅ ។ យី យើ យួ យឿ ។
រៃ រៃ ។ រុ រុំ រំ រាំ ។ រេ រា រៀ ។ លី លើ លួ
លឿ លៀ លា ។ លីលា ។ ល លួ លោ ។ រី រើ រួ
រិះ រេះ ។ រៃយំ ។ គោរោទ៍ ។ រិះរេ ។ រកា ។ រុំដំបៅ ។
ដំរៅ ។ ដំនុំជំរះ ។ ចៅយីលីឈើ ។ យើតាយូរា ។ អាលួ
យំអឺ ។ ពូរឿជិះរទេះគោ ។ អារូលីលា ។ កុំរើរុះ ។ តារី
ជិះលា ។ អាយេរេះទៅ
ណា ។



លា



រូ

ចម្លង – អក្សរផ្ចង់ – ឲ្យសរសេរបំបែកព្យញ្ជនៈខាងលើ

# មេរៀនទី ១១

# ស ហ ឡ

s h l

ឲ្យហាត់រាប់ហា ហើយនឹងធ្វើតួព្យញ្ជនៈទាំង ៣ នេះឲ្យត្រូវស័ន

ស សា សិ សី សឹ សឺ សុ សូ សួ សើ
សឿ សៀ សេ សែ សៃ សោ សៅ សុំ សំ សាំ
សះ ។ សេះ សុះ ។

ហ ហា ហិ ហី ហឹ ហឺ ហុ ហូ ហួ ហើ
ហឿ ហៀ ហេ ហែ ហៃ ហោ ហៅ ហុំ ហំ ហាំ
ហះ ។ ហេះ ហុះ ។

ឡ ឡា ឡិ ឡី ឡឹ ឡឺ ឡុ ឡូ ឡួ ឡើ
ឡឿ ឡៀ ឡេ ឡែ ឡៃ ឡោ ឡៅ ឡុំ ឡំ ឡាំ
ឡះ ។ ឡេះ ឡុះ ។

# ការហាត់

ឲ្យមើលចា ឬឲ្យសរសេរតាមសូត្រ

សា សាំ សោ សៅ ។ សែ សៃ សេ ។ សួ សូ ។ សើ សឿ សៀ ។ ហើ ហឿ ហៀ ។ ហែ ហៃ ។ ហោ ហៅ ។ ហូ ហួ ។ ឡ ឡា ។ ឡោ ឡៅ ។ សី ។ សំឡី ។ សំឡ ។ សរសើរ ។ សរសេរ ។ សសៀរ ។ សេះ ។ ឡេះឡោះ ។ ឡូឡា ។ តាឡេហៅអាសៅ ។

*បម្ង — អក្សរផ្ចង់*

ឲ្យសរសេរព្យញ្ជនៈបំបែកតាមលំដាប់ខាងលើ

# មេរៀនទី ១២

ង៉=ងុ ញ៉=ញុ ន៉=នុ=ណ ម៉=មុ យ៉=យុ

រ៉=រុ ល៉=លុ=ឡ វ៉=វុ ។ ប៉=បុ ប៊ ស៊=សុ ហ៊ ។

| សម្គាល់ពីខាងក្រោម លុះតែកាលណានៅខាងលើមានស្រះបង្អៀតកន្ទែង |
|---|

ង៉ ង៉ា ងុិ ងុី ងុឹ ងុឺ ងុ ងូ ងើុ ង៉េ ង៉ែ ង៉ៃ

ង៉ោ ង៉ៅ ងុំ ង៉ំ ងុាំ ង៉ះ ។ ង៉េះ ងុះ ។

ញ៉ ញ៉ា ញុិ ញុី ញុឹ ញុឺ ញុ ញូ ញើុ ញ៉េ

ញ៉ែ ញ៉ៃ ញ៉ោ ញ៉ៅ ញុំ ញ៉ំ ញុាំ ញ៉ះ ។ ញ៉េះ ញុះ ។

ន៉ ន៉ា ។ ម៉ ម៉ា មុិ មុី មុឹ មុឺ មុ មូ មើុ

ម៉េ ម៉ែ ម៉ៃ ម៉ោ ម៉ៅ មុំ ម៉ំ មុាំ ម៉ះ ។ ម៉េះ មុះ ។

យ៉ យ៉ា យុិ យុី យុឹ យុឺ យុ យូ យើុ យ៉េ យ៉ែ

យ៉ៃ យ៉ោ យ៉ៅ យុំ យ៉ំ យុាំ យ៉ះ ។ យ៉េះ យុះ ។

រ៉ រ៉ា រ៉ិ រ៉ី រ៉ឹ រ៉ឺ រ៉ុ រ៉ូ រ៉ើ រ៉េ រ៉ែ រ៉ៃ រ៉ោ
រ៉ៅ រ៉ុំ រ៉ំ រ៉ាំ រ៉ះ ។

ល៉ ល៉ា ល៉ិ ល៉ី ល៉ឹ ល៉ឺ ល៉ុ ល៉ូ ល៉ើ ល៉េ ល៉ែ
ល៉ៃ ល៉ោ ល៉ៅ ល៉ុំ ល៉ំ ល៉ាំ ល៉ះ ។ ល៉េះ ល៉ះ ។

វ៉ វ៉ា វ៉ិ វ៉ី វ៉ឹ វ៉ឺ វ៉ុ វ៉ូ វ៉ើ វ៉េ វ៉ែ វ៉ៃ វ៉ោ វ៉ៅ ។

ប៉ ប៉ា ប៉ិ ប៉ី ប៉ឹ ប៉ឺ ប៉ុ ប៉ូ ប៉ើ ប៉េ ប៉ែ ប៉ៃ
ប៉ោ ប៉ៅ ប៉ុំ ប៉ំ ប៉ាំ ប៉ះ ។ ប៉េះ ប៉ុះ ។

ប៊ ប៊ា ប៊ិ ប៊ី ប៊ឹ ប៊ឺ ប៊ុ ប៊ូ ប៊ើ ប៊ុំ ។

ស៊ ស៊ា ស៊ិ ស៊ី ស៊ឹ ស៊ឺ ស៊ុ ស៊ូ ស៊ើ ស៊េ ស៊ែ
ស៊ៃ ស៊ោ ស៊ៅ ស៊ុំ ស៊ំ ស៊ាំ ស៊ះ ។ ស៊េះ ស៊ុះ ស៊ុះ ។

ហ៊ ហ៊ា ហ៊ិ ហ៊ី ហ៊ឹ ហ៊ឺ ហ៊ុ ហ៊ូ ហ៊ើ ហ៊េ
ហ៊ែ ហ៊ៃ ហ៊ោ ហ៊ៅ ហ៊ុំ ហ៊ំ ហ៊ាំ ហ៊ះ ។ ហ៊េះ ហ៊ិះ
ហ៊ុះ ។

# ការហាត់

ឲ្យមើលចាំ ឬឲ្យសរសេរតាមសូត្រ

ង៉េះ ង៉ា ង៉ោ ង៉ៅ ង៉ុំ ។ ញ៉ា ញ៉េ ញ៉ែ ញ៉ៃ ។
ម៊ី ម៊ើ ម៉ា ម៉ុំ ម៉ោ ម៉ៅ ម៉ំ ម៉ែ ។ យ៉ា យ៉ៅ យ៉ោ
យ៉ុំ ។ រយ៉ាម៉ែអាម៉ៅ ។ ចៅញ៉ៀជិះដីរ ។ តាម៊ីដើរតាម៉ៅ ។
ប៊ីអ ។ ចាប៊ី ៤ បំប៊ី ។ បំប៉ា ។ អាវ៉ាស៊ីសាប៊ូ ។
ផាហ៊ុំ ។ ទំហ៊ំ ។ ចៅប៊ូហៅអ៊ី ។ ហោប៉ៅខោ ។

# សាឡើងវិញ

ក ខ គ ឃ ង  ច ឆ ជ ឈ ញ  ដ ឋ ឌ
ឍ ណ  ត ថ ទ ធ ន  ប ផ ព ភ ម  យ រ
ល វ ស ហ ឡ ។

ង៉ ញ៉ ន៉ ម៉ យ៉ រ៉ ល៉ វ៉ ប៉ ប៊ ស៊ ហ៊ ។

ក ភ ត គ ។ ច ថ ប ម ហ ។ ជ ផ ដ
ឋ ធ ង ។ ឆ ន ។ ល ស ឈ ណ ។ ព ញ ។
ឃ យ ។ ទ ឡ ។ រ វ ។

អាអ៊ុថាអ៊ី ។ វាថាចៅកែគុំចៅគាំ ។ ចៅខានៅឃុំគគីរ ។ ចៅឆេងងើ ។ តាជាជិះសេះទៅណា ។ ចៃជីខាំដៃអាឋូ ។ ចៅឈុំឈើដៃ ។ តាឌីដាំដំណាំ ។ ដុំដីនេះធំ ។ ទទាទំ នៅលើឈើ ។ គោភរោទ៍ ។ ពពែញីឃំ ។ តាពៅពុះឈើ ។ អាស៊ុំរុំងំប៉ោដែភ ។ ចៅប៊ីស៊ុសាប៊ូ ។ ដីនេះទំហំធំ ។ ម៉ែ អាហ៊ីស៊ុអំពៅ ។ មេឃុំម៉ៅជិះសេះញី ។ ប៊ីញៀវស៊ុញាំទា ។ តាណោបេះបំប៊ុ ។ អាម៉ុហៅអាភ៉ាទៅណា ។

# មេរៀនទី ១៣

ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

អក្សរទាំងប៉ុន្មាននេះ គឺជាស្រៈសំស្រ្កឹត ឬបាលី ដូច្នេះគ្មានផ្សំនឹងសញ្ញាស្រៈឯទៀតទេ

## ការហាត់

ឲ្យមើលចា ឬឲ្យសរសេរតាមសូត្រ



ឫស្សី

ឮឬទេ ។ ឯនេះ ។ ឯនោះ ។

មាបៅឱនៅឯណា ។ នៅឯនោះ ។

ឱអាឱបាអឺ ។

ចម្លង—អក្សរផ្ចង់

ឲ្យសរសេរតួអក្សរខាងលើ

# មេរៀនទី ១៤

## ប្រកបពាក្យ

គ្រប់ព្យញ្ជនៈយកទៅដាក់មុខប្រកបធ្វើជាពាក្យបានទាំងអស់ ត្រូវសង្កត់សំដីលើព្យញ្ជនៈនោះ ។ ឧបមាដូចជា ក នឹង ក ជា កក ។ កា នឹង ក ជា កាក ។ ប នឹង ង ជា បង ។ បា នឹង ត ជា បាត ។ សុ នឹង ខ ជា សុខ ។ បិ នឹង ទ ជា បិទ ។ ប៉ នឹង ង ជា ប៉ង ។ រៀ នឹង ន ជា រៀន ។ ដើ នឹង ម ជា ដើម ។ល។

| ប្រកបពាក្យនឹង ក ឬ ខ គ ឃ |
|---|

អក = អខ = អគ = អឃ

អក អាក អិក អុក អូក អួក អើក
អៀក អេក អែក អោក ។

អ៊ក អ៊ាគ អ៊ិក អ៊ុក អ៊ូក អ៊ួក អ៊ើក
អ៊ៀក អ៊េឃ អ៊ែក អ៊ោក ។

កក កាក បក សក ពិបាក ផឹក សុខ សូក សំណូក បើក បេក បែក ដែក បោក កែកកោក ។

រក យក មក ឆាគ ជីក ទូក ទឹក ទុក ពួក មួក លើក លោក មេឃ មែក ជជែក រោគ ។

ឪពុកចៅសេកដេក ។ អាសុកផឹកទឹកកក ។ ទៅរកដែកយកមកនេះ ។ ម៉ែអាម៉ុកស៊ីបេក ។ ឪពុកវាវែកឪឡឹក ។ កុំយកសំណូកទៅសូកលោក ។ ទុកមួកលើតុ ។ ពពកនៅលើមេឃ ។ មែកឈើបោកលើទូក ។

ចម្លង — អក្សរផ្ចង់
ឲ្យសរសេរពាក្យរាយខាងលើ

# មេរៀនទី ១៥

ប្រកបពាក្យនឹង ច ឬ ជ

អច=អជ

អាច អិច អុច អូច អួច អើច អៀច

អេច អែច អោច ។

អ៊ាច អ៊ិច អ៊ុជ អ៊ូជ អ៊ួច អ៊ើច អ៊ៀច

អ៊េជ អ៊ែច អ៊ោច ។

កាច ដាច សាច អំណាច អុច សុច ហុច តិច តូច ដូច ខូច ហួច សើច បោច ហោច ។ ទិច លិច ពូជ លួច កួច កំនួច មុជ ។

ខោដាច ។ ចៅអ៊ុចសើច ។ សុចខាំ ។ លិចទឹក ។ មុជទឹក ។ ខោចៅអ៊ូចដាច ។ តាតូចហួចហៅអាកុច ។ ពូមៀចសើចអឺ ។ អាធុចគេចវេះ ។ អាខូចទៅរកអាលួច ។

ចម្លង – អក្សរផ្ចង់ – ឲ្យសរសេរពាក្យរាយខាងលើ

# មេរៀនទី ១៦

ប្រកបពាក្យនឹង ត ឬ ដ – ដ្ឋ – ថ – ទ – ធ – ឍ

អត = អដ = អដ្ឋ = អថ = អទ = អធ = អឍ

អត អាត អិទ អុត អូត អួត អើត
អៀត អេត អែត អោត ។

អ៊ត អ៊ាត អ៊ិត អ៊ុត អ៊ូត អ៊ួត អ៊ើត
អ៊ៀត អ៊េត អ៊ែត អ៊ោត ។

កាត សិត បិទ កាំបិត ឥត=ឥដ្ឋ ដុត អួត កើត កំណើត សំប៉ែត សៀត ដោត ឆោត ប៉ោត ។ ជិត គិត គំនិត ពុត ពួត ជួត យឺត ទៀត លោត ពោត ។



កាំបិត

បៅពុតអ៊ុតខោ ។ តាអ៊ិតដុតពោត ។ បៅកេតភូតអាកើត ។ តាអ៊ាតនៅជិតតាផេត ។ បៅម៉េតអួតថាវាលោតពូកែ ។ អាឆូតវាធោតស៊ីពោតឆៅ ។ អាសៅកើតដំបៅនៅគូថ ។ កាំបិតនេះដុតទៅវាលូត ។

ចម្លង–អក្សរផ្ចង់

ឲ្យសរសេរពាក្យភាយខាងលើ

# មេរៀនទី ១៧

ប្រកបពាក្យនឹង ប ឬ ព ភ

អប = អព = អភ

អប្ប អាប អិប អុប អូប អួប អើប
អៀប អេព អែប អោប ។

អ៊ប អ៊ាប អ៊ិប អ៊ុប អ៊ូប អ៊ួប អ៊ើប
អ៊ៀប អ៊េព អ៊ែប អ៊ោភ ។

ជប ជាប បប បាប បិប បុប បួប ឆាប ហិប
ហុប ឃាប ហើប សែព បែប ចោប រសើប ថើប ។
ទាប ទៀប ទេព រាប រៀប លាប លាភ រូប រួប លេប
រលើប ទើប លោភ ។

. ហឹបនេះរលើប ។ ហៅអ៊ិបរសើប ។ តាទេពជិះសេះផត
កែប ។ តាផែបដាំទៀបនៅ
ដីទំនាប ។ អាអ៊ិបឈឺដាប ។
តាបាបយកពោតបីហាបមក ។
គេសាបសំណាប ។ រូបនេះ
ហៅថាកែបសេះ ។



*កែបសេះ*

*ចម្លង — អក្សរផ្ចង់*

ឲ្យសរសេរពាក្យខាងលើ

# មេរៀនទី ១៨

ប្រកបពាក្យនឹង ន ឬ ណ

អន = អណ

អន អាន អិន អុន អូន អួន អើន
អៀន អេន អែន អោន ។

អ៊ន អ៊ាន អ៊ិន អ៊ុណ អ៊ូន អ៊ួន អ៊ើន
អ៊ឿន អ៊ៀន អ៊េន អ៊ែន អ៊ោន ។

បាន ហាន កិន បិន កុន កូន យួន បួន សេន សែន កៀន កើន តើន តឿន ។ មាន មៀន ទាន ទៀន វាន រៀន ទាហ៊ាន មិនហ៊ាន មុន ជូន ពូន ពួន បំនួន លឿន មែន មិនមែន អាភៀន ។ ឱន ។ ខាន ជីដូន ។

បៀន បំពាន លាន លៀន លូន លុន ពុន ហ៊ុន គុណ
ស៊ុន សួន ឈាន ដំហ៊ាន ។

រទេះឡានបិនកិនកូនយួន ។ អាអ៊ួនថា វាមានសេនបួនសែន ។ ប៉ៅកែនថាមិនមែនទេ ។ តាទែនរកស៊ីដាំមៀន ។ កូននេះអៀនពួននៅកៀន ។ ទាហ៊ានម៉ែនមិនហ៊ានទៅមុនលោកទេ ។ តាប៊ុនញៀនអាភៀន ។ ពូគានសូនរូបកូនបិន ។ ដីដូនមានគុណ ។

> ចម្លង—អក្សរផ្ចង់
>
> ឲ្យសរសេរពាក្យភាយខាងលើ

# មេរៀនទី ១៩

ប្រកបពាក្យនឹង ន នឹង ញ

អន អាន អិន អុន អូន....អោន

អ៊ន អ៊ាន អ៊ិន អ៊ុន អ៊ូន....អ៊ោន

អញ អាញ អិញ អុញ អេញ.អោញ

អ៊ញ អ៊ាញ អ៊ិញ អ៊ុញ អ៊េញ.អ៊ោញ

កង បង ខាង ខឹង បឹង ទ្បើង បុង ដូង ។ ទង ណាង លៀង រាង រៀង រឿង លឿង រឹង ទទឹង ធុង លួង លេង លែង ជើង វ៉ែង យើង រោង ឯង ។

បេញ ដេញ ទាញ ទិញ ទំនិញ រុញ ជួញ ជំនួញ ឃើញ ពេញ ។

· យើងទៅលេងឯបឹងកេងកង ។ បងជួងទៅទិញទំនិញ យកមកជូន ។ ជើងចៅអ្ហួញវែងជាងជើងចៅញ៉ុញ ។ តាផែង លេងនៅបុងរោង ។ ឆនោងឡើងបុងដួង ។ បងហួងបង្ករបង ។ ពួឡងដេញពាបី ។ តាមុឺរញផងទាញផង ។ បំណាងនេះ តាម៉ោញផ្ញ ។ ចៅពេញឃើញអាលេញបេញទៅលេង ។

| |
|---|
| *ចម្លង–អក្សរផ្ចង់*<br>ឲ្យសរសេរពាក្យរាយខាងលើ |

# មេរៀនទី ២០

**ប្រកបពាក្យនឹង ម យ រ**

*អម អាម អិម អុម អូម .......អោម*

*អ៉ម អ៉ាម អ៉ិម អ៉ុម អ៉ូម .......អ៉ោម*

*អយ អាយ អុយ អួយ .......អោយ*

*អ៉យ អ៉ាយ អ៉ុយ អ៉ួយ .......អ៉ោយ*

*អរ អារ អូរ អួរ អើរ .......អោរ*

*អ៉រ អ៉ារ អ៉ូរ អ៉ួរ អ៉ើរ .......អ៉ោរ*

កម កំ សម សំ ចាម ចាំ សូម សើម ហើម ផើម បៀម មៀម ឈាម យាម ទឹម ធិម ញញឹម រួម មើម គោម រោម នោម ។ កាយ កៃ ចាយ ចៃ បាយ

---

តាមទម្លាប់សំដីអ្នកស្រុកប្រកបនឹង រ. ហាក់ដូចជាគ្មាន រ. ទេ ។

ហ៊ុយ ហើយ រួចហើយ កើយ សើយ យាយ និយាយ



លាយ រលាយ រ៉ុយ លុយ មួយរយ ជួយ

ភ្ឈួយ · រលួយ ជួយ ងឿយ រឿយ

ឱ្យ = ឲ្យ (ឱយ) ។ ការ សួរ សូរ ជូរ

ដេរ ដែរ ដើរ ហូរ ហូរហែ សរសេរ

ដោរ ជួរ ជួរ យូរ យួរ ។

ទីទុយ



សម

រុយរោមឈាម ។ បងជាមទិញគោមួយនឹម ។ ចៅឈិមសើចញញឹម ។ ពូទិមទិញជួយមួយ ។ លោកភ្ឈួយមានបៀមមួយរយ ។ ចៅស៊ិយស៊ីបាយរួចហើយ ។

ចម្លង – អក្សរផ្ចង់

ឲ្យសរសេរពាក្យខាងលើ

# មេរៀនទី ២១

ប្រកបពាក្យនឹង ល រ ស

អល អាល អិល អុល អូល ..អោល ។

អ៊ល អ៊ាល អ៊ិល អ៊ុល អ៊ូល ..អ៊ោល ។

អរ អារ អិរ អូរ អេរ អែរ .....អៀរ ។

អ៊រ អ៊ារ អ៊ិរ អ៊េរ អ៊ែរ .....អ៊ៀរ ។

អស អាស អិស អុស អូស ...អោស ។

អ៊ស អ៊ាស អ៊ិស អ៊ុស អ៊ូស ...អ៊ោស ។

កាលណា អំបិល សិល បួល ជួល ដួល ដែល ហែលទឹក ពោល បោល មូល មួល រមួល កំសួល ធួល ឈើមួល ទទួល មើល ពាល រៀល យោល រំយោល ។ អារ ការ បារ បៅ សាហារ រដូវ មិនសូវ កែរ ពែរ

ឈាវ ។ បាស បោស កោស ខុស បេស លួស ជំនួស
លើស រើស ទោស រមាស ។



ថាស

គេជួលតាឈាវរែកអំបិល ។ ពូម៉ុលចែវទូក ។ ដើមឈូកនេះយោលទៅយោលមក ។ សេះតាពុកបោលមិនសូវលឿនទេ ។ កាលណាឯងទំនេរឯងទៅហែលទឹកជាមួយនឹងអញ ។ ចៅម៉ាញទទួលទោសជំនួសចៅមាស ។

ចម្លង — អក្សរផ្ចង់
ឲ្យសរសេរពាក្យរាយខាងលើ

# មេរៀនទី ២២

## សង្កត់

សង្កត់គឺសញ្ញានេះ សម្រាប់ដាក់លើព្យញ្ជនៈប្រកប អាចឲ្យពាក្យដែលកើតដោយអក្សរសំដីវែង បានទៅជាពាក្យសំដីដាច់ខ្លី ឧបមាដូចក្នុងពាក្យ កក ទៅជា កក់ ; កាក ទៅជា កាក់ ; ចង ទៅជា ចង់ ; តាប ទៅជា តាប់ ។ល។

អក់ អាក់ អង់ អាច់ អាញ់ អត់ អាត់ អន់ អាន់ អប់ អាប់ អល់ អាល់ អស់ អាស់ ។

អ៊ក់ អ៊ង់ អ៊ច់ អ៊ញ់ អ៊ត់ អ៊ន់ អ៊ប់ អ៊ល់ អ៊ស់ ។

អ៊ាក់ អ៊ាត់ អ៊ាន់ អ៊ាប់ អ៊ាល់ អ៊ាស់ ។

កក់ សក់ កាក់ កង់ ចង់ កត់ កាត់ ដាប់ សាប់ បាញ់ បាញ់ កាន់ កប់ កាប់ កល់ សល់ ដាល់ បាស់ ណាស់។

គក់ ជក់ គង់ ទង់ ទប់ លញ់ លត់ រត់ ទន់ ជន់ ឈប់ យប់ គល់ ទល់ យល់ ពស់ រស់ ។

ជាក់ ពាក់ រាក់ ឆាក់ = អ្នក មាត់ ជាត់ មាន់ ទាន់ ងាប់ ជាប់ ទាល់ ពាល់ គាស់ រាស់ រមាស់ ។



សំណាញ់

ឈើនេះបាក់ជាដប់កំណាត់ ។ តាផាត់ទៅបង់សំណាញ់ជាមួយនឹងសំឡាញ់គាត់ ។ ពូរាត់ទៅទាក់មាន់ ។ ចៅរាល់សរសេរភាន់ ។ រាល់ពេលពូហាស់លើរនាស់ទៅរាស់ដី ។ គេសំគាល់ថាអ្នកណាជាត់ពេកឆាប់ងាប់ ។ កូនយួនពីរនាក់នេះកើតរមាស់ ។ មេផែនទីទៅរាស់ដីរបស់តាលន់ ។

ចម្លង — *អក្សរផ្ចង់* — ឲ្យសរសេរពាក្យខាងលើ

# មេរៀនទី ២៣

តាមទម្លាប់ បើកាលណាមានពាក្យសំដីដែលត្រូវឲ្យសរសេរ អាង៑ គេប្រើយ៉ាងនេះវិញគឺ អាំង ។

អាំង អ៊ាំង

អោះ អ៊ោះ

តាំង បាំង ចាំង សាំង បំបាំង ចាំង អាំង រមាំង ភាំងគគ ទាំងអស់ ទំពាំង ភាំង រគាំង រាំង រនាំង បាំង បំបាំង ភាំង ។



កោះ

កោះ ចោះ បោះ បោះបង់ ដោះ ហោះ សោះ ៗ ឈើពោះ លោះ ពីរោះ បំពោះ ទោះ នោះ ពស់វែក ។

· ចៅសាំងស៊ីសាប់គោអាំង ។ ម៉ែចៅកាំងទៅទិញទំពាំង ឯកោះវះ ។ យើគេវាយរគាំងហើយតើ ។ អាតាំងវ៉ាតៅបៅ ដោះម៉ែវ៉ា ។ បិនបាំងឈើពោះ ។ ពូដាំងបេះនិយាយពីរោះ ។ តានោះបាំងតាំងយូទៅកោះ ។ ហាមឡ៉ាះមិនឲអឺសោះ ។ គេបោះរគាំងបូលទៅទីកំបាំង ។ តាផាំងបងវាំងននបាំង ។

ចម្ងន់ - អក្សរផ្ចង់
ឲ្យសរសេរពាក្យភាយខាងលើ

## សរុបនិទ្ទេស

ឲ្យមើលជា ឬឲ្យសរសេរតាមជា

ដឹកទឹកកកមួយកែវ ។ ដេកយប់កុំដេកយូរ ។ យកមួកមកនេះ ។ អ្នកទុកសំពត់នៅឯណា ។ យកអាវទៅឯនោះ ។ អស់បាយហើយឬនៅ ។ អស់ហើយ ។ នៅ មិនទាន់អស់ទេ ។ ដល់ម៉ោងហើយឬនៅ ។ ដល់ម៉ោងហើយ ។ ហួសម៉ោងហើយ ។ មិនទាន់ដល់ម៉ោងទេ ។ មើលឯនេះ ។ ឃើញឬទេ ។ មិនឃើញទេ ។ ឃើញហើយ ។ ឮឬទេ ។ យល់ហើយឬនៅ ។ មិនទាន់យល់ទេ ។ អ្នកយកកាំបិតនេះទៅឲ្យទាហានប៉ែន ។ ឯងយកសៀវភៅនេះទៅជូនលោកភូឈួយ ។ មានកូនកាត់ចិនបួននាក់ទៅកាត់សក់ ។ ដំរីសាហាវកុំដើរទៅជិតវា ។ ទាធំជាងមាន់ ។ អ្នកមកសាលារៀនឲ្យទាន់ពេលវេលា ។ ជីតាយើងនៅរស់ទេ ។ អ្នកគួរតែខំរៀនឲ្យមែនទែន ។ ចៅទីបេះគួរសមជាងចៅទុំ ។ នាយសំខំបំរើម៉ែវា ។ ចៅសុខបេះសំអាតខោអាវវា ។

# ពាក្យសំដីប្រហែលគ្នា

កី កែ ។ កូរ កោរ គោ គូរ ។ ទុក ទូក ។ ពុក ពូក
ពួក ពក ។ លុក លូក លក លក់ ។ ចាយ ចៃ ជៃ ។
ចាម ចាំ ។ ចាវ ចៅ ។ ជាវ ជៅ ។ ជាប ជាប់ ។
ជល់ ជាល់ ។ សង សង់ សាង ។ កង កង់ ។ បង
បង់ បាំង ។ ចង ចង់ ចាំង ។ ទង ទង់ ទាំង ។ លង
លង់ ។ លេង លែង ។ រីង រឹង រឿង រូង រោង រង ។
ជូរ ជួរ ជឿ ។ នំ នោម នាំ ។ រុំ រោម រាំ ។
គុំ គំ ។ ទុំ ទំ ។ ឈាង ឈៀង ឈឿង ឈួង ។
ឈាន ឈៀន ឈឿន ឈាន់ ។ មាន មៀន មាន់ ។
ទាន ទៀន ទាន់ ។ រាន រៀន ។ រាង រៀង រាំង ។ ទាប
ទៀប ទាប់ ។ រាប រៀប រាប់ ។ រមាស រមាស់ ។
ទាគ ទាក់ ។ ទាល ទាល់ ។ បេស បេះ ។ កត់ កាត
កាត់ កំណត់ កំណាត់ ។

# ពាក្យដាក់ជាក្រុមតាមខ្យល់សំដី

## ខ្យល់ អ

អរ អក អម កម កក កករ កង ខម បង ដក ដង ឌប តប តម ចត បរ បង ប៉ង បបរ ផង ផត ឡ ឡក ឡត សក សង សម សរ ។

## ខ្យល់ អ៊

គរ គង គម ងរ ជរ ឈរ ទរ ទត នគរ ពង ពួក ពពក ពរ ភរ មរ មក មន យក រក រយ លង លលក រលក ។

## ខ្យល់ អា

អាប អាប អារ រណារ អាហារ ការ កាប កាល កាស ខាង ខាន បាន បាប ដាន តាម ឯណា បាន បាយ បាប ឆាយ ឡាន សាប ហា ។

## ខ្យល់ អ៊ា

គាប ងារ ងាយ ជាយ ជាង ជាល ឈាន ឈាម វិញ្ញាណ ទា ទាញ ទាន ទាប នាម នាយ ជើងពាន ភាគ ភាព មាន យាន យាម រាន រាជ រាប លា លាន វា វាយ ហ៊ាន ។

## ខ្យល់ អិ = ឥ

ឥត បំអិន កិន ចិន តិប ដិត ប៉ិប ប៉ិន បិទ សិក សិន សិល ហិត ហិន ។

## ខ្យល់ អ៊ិ

ជិត ជិះ ទិញ ទិប មិន ទំនិញ លិច លិប វិញ វិល ។

## ខ្យល់ អី

កី ដី• បី ប៉ី សី សំដី សំឡី ឌី ។

## ខ្យល់ អ៊ី

ជី ជីក ជីវិត ញី ទី ពី ពីរ ពីសា មីង រីក លី លីង លីលា ពីរោះ ។

ខ្យល់ អឹ

ខឹង ដឹង តឹង បឹង បឹក ដឹក ផឹក សឹក ។

ខ្យល់ អឹ

មឹត ទឹក ឆឹក ឆឹង មឹន ពឹង រឹង ទទឹង ងងឹត ជំរឹត ។

ខ្យល់ អឺ

បឺម ធឺង ណឺង តឺង បឺត មុឺន ហឺត ឡឺត ។

ខ្យល់ អឺ

គឺ ឈឺ ឬ (រឺ) យឺត រឺត ។

ខ្យល់ អុ = ឧ

អុប ឧបាយ កុសល កុន ខុប បុង ផុង ឆុត ជុត តុ ប៊ុន ប៊ុយ ផុយ ធុត សុខ សុប ហុង ហុប ហុយ បំហុយ ។

ខ្យល់ អ៊ុ

គុក គុណ ជុក ទុក ទុក្ខ ទុង ទីទុយ ធុយ ពុត ពុន មុខ មុជ មុន រុញ រុយ លុក លុយ លុន ។

ខ្យល់ អូ

អូរ អូស កូរ កូត កូន កូឡាប ខូង ខូប បូក បូល ឆូត ដីដូន ដូង ដូច ដូរ តូប បូក បូជា បូស សូម សូរ ហូត ហូប ហូរ ។

ខ្យល់ អ៊ូ

គូរ ងូត ជូត ជូន ជូរ ឈូក ឈូស ទូរ ទូប ទូក ទូល ទូ ធូប ធូលី ធូរ ពូក ពូជ ពូត ពូន ភូត មូរ មូល មូស យូរ រូង រូប លូ លូន ។

ខ្យល់ អួ

អួត អួន អួល កួប ខួរ ខួប ឆួល ដួន ដួល ដួស បួរ បួន បួស សួត សួរ ហួប ហួស ។

ខ្យល់ អ៊ួ

គួរ គួប ជួង ជួញ ជួត ជួប ជួន ជួល ជួរ ជួស ទួញ ទំនួញ ទួល ទទួល ធួន ពួន ពួរ ពួក ពួយ ជួយ មួក មួយ យួន រួប លួង លួប ។

ខ្យល់- អើ

អើត កើត កើយ ធើត តើ តើន ដើរ ដើម ផើម បើ បើក បុើង បំបើង ឡើង ឡើយ សើយ សើប រសើប សរសើរ សើម ហើម ហើរ ហើយ ។

ខ្យល់ អើ

ឃើញ ងើប ងើយ ឈើ ញើស ទើស ទើប អំពើ មើល មើម យើង រើ រើស លើ លើក លើស ។

ខ្យល់ អៀ

អៀន កៀន កៀក ខៀវ បៀម បៀន ផៀង ដៀល បៀ បៀក សៀត សៀម ហៀប ។

ខ្យល់ អៀ

ងៀង ងៀត ញៀន ទៀង ទៀត ទៀន ទៀប ពៀប ពៀប ពៀរ មៀន មៀម រៀង រៀល លៀន លៀង លៀស វៀប វៀន ។

## ខ្យល់ អឿ

ខឿន ជឿ ជឿន តឿ តឿន ឆឿយ ជឿក រឿង រុងរឿង លឿង លឿន ។

## ខ្យល់ អេ

កេរ កកេរ បេក បេស បេញ ដេញ ដេក ដេរ ឡេវ លេខ សរសេរ ។

## ខ្យល់ អេ

គេ ជេរ ទេ នេន ទំនេរ ពេក ពេញ ពេប ពេល ភេ មេ លេខ លេង លេប លេប វេប វេញ វេទនា ។

## ខ្យល់ អែ=ឯ

ឯ ឯង កែង កែវ ខែ បែក បែវ ឆែក ដែក ដែល ដែរ តែ តែង តែងតែ ថែ ថែម ណែន បែរ បែក ប៉ែក បែង បែន បែប ផែន ម៉ែញ សែង សែន សែស ហែក ហែល ចំឡែក ។

## ខ្យល់ អ៊ែ

គែ គែម ញែក ជដែក ពែ ពពែ ពែង មែក
មែឆ វែក វ៉ែង លែង ស៊ែង ប៉ែក ។

## ខ្យល់ អៃ

អាឡៃ កៃ ខៃ បៃ ដៃ សរសៃ ដំឡៃ សំបៃ ។

## ខ្យល់អាយ (កុំច្រឡំនឹងខ្យល់អៃ)

ឯអាយ កាយ ចាយ ឆាយ បាយ ផាយ សាយ ។

## ខ្យល់ អ៊ៃ

គៃ ទៃ ទីទៃ នៃ រំពៃ ភៃ បំភៃ វៃ លៃ
វ៉ៃ រវ៉ៃ ។

## ខ្យល់ អោ ឱ–ឲ

ឱន ឱប កោរ កោប កោង កោត ខោ ចោត
ចោល ចោរ ឆោត ដោត ដោក ដោយ តោង ថោក
បោក បោល ប៉ោត ប៉ោង បោប បោស អំបោស សោ
សោក សោយ ហោប ។

## ខ្យល់ អោ៑

គោ គោម គោល ង៉ោក ជោក ជោរ ជំនោរ ឈោង ទោង ទោស ផេងផោង នោម ពោរ ពោង យោង យោល រោង រោល រោយ រោម លោ លោក លោត លោភ លោម ។

## ខ្យល់ អៅ

កៅអី ចៅ ឆៅ តៅ បៅ បំបៅ ហៅ សំដៅ កំដៅ ដំបៅ ពូថៅ ។

## ខ្យល់ អារ (កុំច្រឡំនឹងខ្យល់ អៅ)

អារ ការ ងារ បារ ជារ សាហារ ។

## ខ្យល់ អៅ៑

អំពៅ យោរយៅ ទៅ នៅ ពៅ សំពៅ សៀវភៅ ជំរៅ លំនៅ ។

# មេរៀនទី ២៤

## ជើងព្យញ្ជនៈ

គ្រប់ព្យញ្ជនៈតែងតែមានជើងសំរាប់ផ្ញើពីក្រោមព្យញ្ជនៈឯទៀត បញ្ចូលសំដីគ្នាហាក់ដូចជាមានព្យញ្ជនៈតែមួយរូប ។ ដូច្នេះពួកផ្ញើជើងទាំងប៉ុន្មានក៏ត្រូវផ្សំនឹងស្រៈដូចព្យញ្ជនៈនានាដែរ ។ ប៉ុន្តែត្រូវចាំថា មានព្យញ្ជនៈមួយពួក សំដីលំអានបានទៅជាពីរយ៉ាង គឺពួក ង ញ ន ម យ រ ល វ ពួកនេះ បើយកទៅផ្ញើនឹងតួព្យញ្ជនៈណាមួយ សំដីវាក៏ដួលតាមព្យញ្ជនៈនោះ ឧបមាដូចជា ន ផ្ញើនឹង ខ បានទៅជា ខ្ន (នទៅជាន៉) ។ ក្រៅពីពួក ៨ តួនេះ ជាព្យញ្ជនៈសំដីរឹង ទោះយកទៅផ្ញើនឹងតួព្យញ្ជនៈណាៗក្តី វាទាញសំឡេងគេទៅតាមសភាពរបស់ខ្លួន ឧបមាដូចជា ប ផ្ញើនឹង ម នៅតែសំឡេង ប ដដែល (ម្ប) គ ផ្ញើនឹង ស នៅតែសំឡេង គ ដដែល (ស្គ) ។ ព្យញ្ជនៈខាងក្រោមនេះ ច្រើនតែយកជើងទៅផ្ញើនឹងព្យញ្ជនៈឯទៀត ។

ព្យញ្ជនៈសំដីដួលតាមព្យញ្ជនៈដែលវាទៅផ្ញើ គឺ ង្ង ញ្ញ ន្ន ម្ម យ្យ ្រ ល្ល វ្វ ។

ព្យញ្ជនៈសំដីរឹងទាញសំឡេងគេតាមសភាពរបស់ខ្លួនវិញ គឺ ក្ក ប្ប ដ្ដ ប្យ ស្យ ហ្ហ គ្គ ដ្ឋ ទ្ទ ព្ព ។

# ផ្ញើជើង

| |
|---|
| យើងតាំងដំបូងអំពីជើង ្រ ។ ក្នុងផ្ញើជើង ្រ នេះ គេច្រើនហៅថាក្រវាត់ដៃ ។<br>ឲ្យចំណាំថាអក្សរ ប បើមានអក្សរឯទៀតមកផ្ញើផង ឲ្យលុប ប ទៅជា ប៉ ។ |

ក្រ ច្រ ត្រ ប្រ ស្រ ។ គ្រ ជ្រ ទ្រ ព្រ ម្រ ។

ក្រៅ ក្រោយ ក្រោម ក្របី អាក្រក់ ។ ច្រើន ច្រូត ។ ត្រី ត្រា ត្រើយ ត្រូវ ត្រឹមត្រូវ ។ ប្រើ ប្រែ ប្រុស ប្រក់ ប្រាក់ ប្រាប់ ។ ស្រា ស្រី ស្រូវ ស្រុក ស្រាល ស្រួល ស្រេក ស្រែក ស្រោប ។ គ្រូ គ្រែ គ្រប គ្រប់ គ្រាប់ ។ ជ្រៅ ជ្រក ជ្រះ ជ្រុះ ជ្រូក ជ្រុង ។ ទ្រុង ទ្រនំ ទ្រនាប់ ទ្រេតទ្រោត ។ ព្រឹក ព្រៃ ព្រើល ព្រាប កំព្រា ព្រានព្រៃ ព្រះ ព្រុះ ពីព្រោះ ។ ម្រះ ម្រោម ម្រេប ម្រាម ។

ក្របីស៊ីស្រូវ ។ ស្រីស្រុកស្រែច្រូតស្រូវ ។ អ្នកនេះស្រវឹងស្រាដើរទ្រេតទ្រោត ។ ចៅក្រមនេះត្រឹមត្រូវទេ ។ ព្រានទៅ

បាញ់ជ្រូកព្រៃនៅក្រោមដើមជ្រៃ ។ តាព្រាបកូតទ្រ ។ ស្រីនេះ



ជ្រៃ

ដងទឹកស្រោចដំណាំ ។ គេ
ក្រាលពូកនៅលើគ្រែ ។

ទឹកឡើងត្រីស៊ីស្រមោច
ទឹកហោចស្រមោចស៊ីត្រី ។
ទឹកត្រជាក់ត្រីកុំ ។ នៅលើ
ទ្រនាប់ហើយនឹងញញួរកុំយក
ម្រាមដៃទៅដាក់ ។

*ចម្លង — អក្សរផ្ចង់*

ឲ្យសរសេរគ្រវាត់ខាងលើ ហើយនឹងពាក្យរាយ ។

# មេរៀនទី ២៥

ង្ង ញ្ញ ន្ន ម្ម យ្យ រ្រ ល្ល វ្វ ។

អ ក្ក ច្ច ដ្ដ ប្ប ស្ស ហ្ហ គ្គ ជ្ជ ធ្ធ ព្ព ។

ក្អ ក្ង ក្ន ក្ម ក្ល ក្វ ក្ដ ក្ប ក្ស ។

ខ្ញ ខ្ន ខ្ម ខ្ល ខ្វ ខ្យ ខ្ស ខ្ច ខ្ជ ខ្ដ ខ្ធ ខ្ព ។

គ្ន គ្ម គ្ល គ្វ ។ ឃ្ន ឃ្ម ឃ្ល ឃ្វ ។

ក្អម ក្អែក ក្ងាន ក្ងោក ក្នុង ក្មេង ក្លែងក្លាយ ក្ដារ ក្ដាន់ ក្ដៅ ។

---

ឲ្យចំណាំ ១ ១ — ព្យញ្ជនៈណាដែលកំណើតគ្មានខ្យល់ ហ ចូលផង ដូចជា ក (ព្យញ្ជនៈសិថិល) នោះ ដល់ប្រើក្នុងផ្ញើជើងទៅ មានខ្យល់ ហ បន្តិចចូលផង (ខ្យល់ធនិត) ដូចជា ក្ន សំដីប្រែទៅជាប្រហែល ខ្ន ។

១ ២ — ជើងព្យញ្ជនៈណាដែលឡើងទៅលើស្មើនឹងព្យញ្ជនៈ នោះដល់ប្រើនឹងស្រៈ "រុកសក់ដូចជា ិ ី ឹ ឺ ហើយនឹងស្រៈ "ទាញយារ" ស្រៈទាំងនេះត្រូវនៅជាមួយនឹងជើងនោះ ដូចជា ខ្សឹប ផ្សើម ផ្សារ ផ្សោត ក្បាច់ ។ល។

ក្អួប ក្ដាប់ ក្ដាត ក្បាល ក្បែរ ក្បាប់ ក្បោះក្បាយ ក្បាប់ក្បូរ ។

ខ្ញុំ ខ្ញី ខ្នង ខ្នរ ខ្នើយ ខ្មែរ ខ្មៅ ខ្មោច ខ្លាប ខ្លា ខ្វន ខ្វះ ខ្វែក ខ្វាត់ខ្វែង ខ្យល់ ខ្យង ខ្សាប់ ខ្សឹប ខ្សែ ខ្សោយ ខ្ចី ខ្ចៅ ខ្ជិល ខ្ជីខ្ជា ខ្ដត ខ្ទឹម ខ្ទម ខ្ពស់ ខ្ពើម ។

គ្នា ជាមួយគ្នា គ្នាន់គ្នេរ គ្មាន ។ ឃ្មុំ ខ្លាឃ្មុំ ឃ្មោះ ឃ្វាលគោ ឃ្លាត ។

ក្អេងក្អាង ។ ក្អាកក្អាយ ។ ខ្នះខ្នែង មាន់ខ្ដត ។ ខ្មីឃ្មាត ។ ក្មេងខ្លាចខ្មោច ។ ខ្មែរខ្លះខ្លាចខ្មោចជាងខ្លា ។ កុំនិយាយក្អេងក្អាង ។ កុំបែរខ្នងឲ្យខ្ញុំ ។ ស្រីខ្មែរពាក់អាវខ្មៅប្រត ស្រូវក្នុងស្រែ ។ ខ្លាឃ្មុំស៊ីតែទឹកឃ្មុំ ។ ខ្យល់បក់រលំខ្ទមមួយនៅក្បែរត្រពាំង ។ ក្មេងនេះខ្ជិលងូតទឹក គេខ្ពើមវាណាស់ ។ ស្រុកខ្មែរក្ដៅជាងស្រុកបារាំង ។

*ចម្លង – អក្សរផ្ចង់*

ឲ្យសរសេរព្យញ្ជនៈខាងលើព្រមទាំងជើងផង ហើយនឹងពាក្យរាយ



ខ្ទួយ



ខ្សែព្រួរ



ខ្លាឃ្មុំ



ខ្លា

# មេរៀនទី ២៦

ង្ង ញ្ញ ន្ន ម្ម យ្យ រ្រ ល្ល វ្វ ។

អ ក្ក ច្ច ដ្ដ ប្ប ស្ស ហ្ហ ត្ត ដ្ឋ ទ្ធ ព្ព ។

ប្ប ។ ឆ្អ ឆ្ក ឆ្ដ ឆ្ង ឆ្ន ឆ្ម ឆ្ល ឆ្វ ឆ្គ ឆ្ព ។

ដ្វ ។ ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ ។ ត្អ ត្ន

ត្ម ត្ល ត្វ ត្យ ។

ថ្ប ថ្ង ថ្ន ថ្ម ថ្ល ថ្វ ថ្ក ថ្ព ។ ទ្វ ។

ឃ្ង ឃ្ន ឃ្ម ឃ្ល ឃ្វ ឃ្យ ឃ្ដ ។

ប្ញាប់ ប្ញាស់ ប្ញង ប្ញាំង ប្ញុក ប្ញារ ។ ឆ្អឹង ឆ្អែត ឆ្កែ ឆ្កា ឆ្កោក ឆ្ងាញ់ ឆ្ងាយ ឆ្ងល់ ឆ្នេរ ឆ្នៃ ឆ្នោត ឆ្នាំ ឆ្នាំង ឆ្មា ឆ្មើង ឆ្លាត ឆ្លុះ ឆ្លេឆ្លា ឆ្វេង ឆ្គាំឆ្គង ឆ្ពោះទៅ ត្រីឆ្ដោ ។ ថ្វា ។ ឈ្នះ ឈ្នួល ឈ្មោះ ឈ្មោល ឈ្លួស ឈ្លោះគ្នា ឈ្វេងយល់ ។

ត្នោត ត្នាត ត្បាញ ត្បូង ត្អូញត្អែរ ។ ថ្ងៃ ថ្ងាស ថ្នាំ ថ្នល់ ថ្ងាយ ថ្វីដៃ ថ្មី ថ្លា ថ្កុំថ្កើង ថ្គាម ។ ទ្វារ ។ ធ្ងន់ ធ្នាប់ ធ្មេញ ធ្លា ធ្លាយ ធ្លុះ ធ្វើ ធ្វេស ធ្យូង ។ ធ្នុង ធ្នប់ ធ្លាប់ ។

ផ្កែឈ្នោលនេះជេញខាំឆ្មាញី ឆ្មារត់ឡើងដើមក្របឆ្មារ ។ អ្នកឡើងបានតែបេះ អ្នកប្រឡេះបានស៊ីឆ្អែត ។ នៅស្រុកកំពង់-ឆ្នាំងគេធ្វើក្អមឆ្នាំង ។ ស្រីថ្វាពីរនាក់ឈ្លោះគ្នានៅទីធ្លា ។ ថ្ងៃនេះក្តៅណាស់ ។ នៅស្រុកស្រែគេដាំដើមត្នោតច្រើន ។ ក្មេងនេះឆ្លាតណាស់ ។ ស្រីនេះស៊ីឈ្នួលត្បាញសំពត់ឲ្យគេ ។ គោឈ្នោលនេះឆ្លងថ្នល់ទៅខាងត្បូង ។ ស្រុកខ្មែរពីដើមថ្កុំថ្កើងណាស់ ។ ក្មេងនេះឈឺថ្ងាសផង ឈឺធ្មេញផង ហើយនឹងថ្គាមផង ។

*ចម្ងន់ — អក្សរធ្ងន់*

ឲ្យសរសេរព្យញ្ជនៈខាងលើព្រមទាំងជើងផង ហើយនឹងពាក្យរាយ

# មេរៀនទី ២៧

ន្ង ញ្ញ ន្ន ម្ព យ្យ ្រ ល្វ វ្ង ។

អ ក្ក ច្ឆ ដ្ដ ប្យ ស្យ ហ្ហ ភ្ក ដ្ឋ ទ្ធ ព្ឍ ។

ប្អ ប្ដ ប្វ ។ ដ្អ ដ្ង ដ្ញ ដ្ន ដ្វ ដ្យ ដ្ដ

ដ្ក ដ្ក ដ្ឋ ដ្ធ ។ ព្ន ព្វ ព្យ ។ ភ្ង ភ្ញ ភ្ន ភ្វ

ភ្ឋ ។ ម្អ ម្ក ម្ខ ម្ឆ ម្យ ម្ន ម្វ ម្យ ម្ធ ម្ឋ ម្ដ ម្ហ ។

ល្អ ល្ប ល្ហ ល្ង ល្ព ល្វ ។ ស្ង ស្ញ ស្ន ស្ព

ស្វ ស្វ ស្អ ស្ក ស្ដ ស្ប ស្ក ស្ធ ស្ឍ ។ ហ្វ ។

ប្អូន ប្ដី ប្លន់ ប្លោក ប្លែក ។ ផ្អែម ផ្អើល ផ្ដេសផ្ដាស

ផ្ញើ ផ្និត់ ផ្សរ ផ្លែ ផ្លិត ផ្សារ ផ្សែង ផ្សេង ផ្កា ផ្គរ ផ្ធុះ

ផ្ទុះ ផ្ចិតផ្ចង់ ។ ព្នង ព្យុះ ព្យួរ ព្លីការ ។ ភ្ញៀវ ភ្នំពេញ

ភ្នែក ភ្លើង ភ្លឺ ភ្នក់ ភ្ជួរ ។ ម្អម ម្ចាស់ ជួបម្ដេច ម្សៅ ម្នាស់

ម្នឹម្នា ម្លូ ម្លប់ ម្ទេស ម្ជូរ ដើមម្កាក់ ម្ខាង ម្ហូប ។ ល្ខោន ល្អ

ល្បែង ល្មម ល្វ ល្វា ល្ហុង ។ ស្អែក ស្អប់ ស្អុយ ស្នាម ស្នប់

ស្នាប ស្ទូក ស្មា ស្មើ ស្លា ស្លាប់ ស្លាប ស្វៀម ស្វាត់ ស្វោរ

ស្វា ស្វិត ស្ដាប់ ស្ដេច ស្ដើង ស្ដាំ ស្បែក ស្ករ ស្គរ ស្គម

ស្ការ ស្បថ ។ ស្ពែ ស្ពឹក ស្វាប ស្វុះ ស្វែ ស្វើរ ស្ជួង ស្ពាន

ស្ពី ។ ចៅហ្វាយ ចាងហ្វាង ហ្វឹកហ្វឺន ហ្វូង ។ អ្វី ។

ស្វានៅក្នុងព្រៃស៊ីតែស្លឹកឈើ ហើយនឹងផ្លែឈើ ។ ផ្លូវថ្នល់នេះមិនទាន់ក្រាលថ្មទេ ។ ផ្ទះខ្ញុំនៅក្បែរផ្សារ ។ នៅស្រុកខ្មែរគេធ្វើស្ករពីទឹកត្នោត ។ ដល់ម៉ោងធ្វើការគេវាយស្គរ ។ ពេលភ្លៀងច្រើន តែងតែមានផ្គរហើយនឹងព្យុះផង ។ ព្នងនេះដើរតាមផ្លូវបាលភ្លៀង ។ កុំយកជើងទៅជាន់ភ្នក់ភ្លើង ។ កាលណាសរសេរ ត្រូវផ្ទៀងមើលឡើងវិញឲ្យច្បាស់ ។ ត្រូវរៀនមេរៀនឲ្យចាំស្ទាត់ ។ អ្នកនេះឈឺស្ពឹកស្មា ។

ច្បាប់ ។ ល្ងាចនេះ យើងទៅលេងល្បែងជាមួយនឹងគេ ។ ម្ជុលទុកឲ្យគង់ ប្រាក់ក្នុងថង់ទុកឲ្យជា ។ ឆ្កែខាំឲ្យរកម្ចាស់ ។ បើគេនិយាយអ្វី ត្រូវស្តាប់ឲ្យច្បាស់ ។ កាលណាធ្លាក់ភ្លៀង អ្នកស្រែភ្ជួរដីដាំដំណាំ ។ ស្រីនេះម្នីម្នាទៅផ្សារទិញស្ពៃ ម្នាស់ ម្ទេស ម្អមហើយនឹងម្សៅលាបមុខផង ។ ស្រីល្អច្រើនចាញ់ប្ដី ។

ចម្លង–អក្សរផ្ចង់

ឲ្យសរសេរព្យញ្ជនៈខាងលើ ព្រមទាំងជើងផង ហើយនឹងពាក្យភាយ



ផ្ទះ



ស្វា



អ្នកស្រែភ្ជួរ

# សរុបនិទ្ទេស

មើលៗ ឬសរសេរតាមសូត្រ

ក្របីស៊ីស្រូវក្នុងស្រែ ។ ស្រីខ្មែរពាក់អាវខ្មៅច្រូតស្រូវហាលថ្ងៃក្ដៅ ។ ខ្ញុំមានបងប្រុសម្នាក់ ហើយនឹងប្អូនស្រីពីរនាក់ ។ ចិនស៊ីសាច់ជ្រូកច្រើនណាស់ ។ ចៅក្រមនេះត្រឹមត្រូវទេ ។ ខ្មែរខ្លះខ្លាចខ្មោចជាងខ្លា ។ ថ្ងៃនេះខ្ញុំឈឺក្បាលណាស់ ហើយថែមទាំងមានរោគក្អកផង ។ ស្អែកខ្ញុំទៅលេងស្រុកស្រែ ហើយខានស្អែក ខ្ញុំត្រឡប់មកក្រុងភ្នំពេញវិញ ។ ល្ងាចនេះខ្ញុំស្រេកទឹកជាងឃ្លានបាយ ។ កូនល្អមិនធ្វើឲ្យឪពុកម្ដាយព្រួយទេ ។ គ្រូពេទ្យរុំដៃចៅកូនក្មេងម្នាក់ ។ ត្រីឆ្ដោប្រឹងហែលដេញត្រីក្រាញ់ ។ ផ្លែក្រវាញប្រើជាថ្នាំពូកែណាស់ ។ ក្អែកទឹកមុជចាប់ត្រីជាអាហារ ។ ឆ្កែឆ្កួតខាំក្មេងពីរនាក់ស្លាប់ ។ មឹះៗកេះផ្នាំងបាយផ្ទះ ។ នៅស្រុកក្ដៅគេពាក់អាវសស្ដើង ។ នៅប្រទេសរងាគេពាក់អាវសាក្លាតខ្មៅក្រាស់ ។ ខ្មែរស្លៀកសំពត់ចងក្បិន ។ ប្លង់ចង់ស្ដាប់ច្រៀន ។ ខ្ញុំចង់ចងក្បិនរត់ ។

# មេរៀនទី ២៨

## ពាក្យពីរព្យាង្គ

ដែលហៅថា ពាក្យពីរព្យាង្គ គឺពាក្យចេញជាសំនីពីរម៉ាត់ហើយរួមមកបានជារូបពាក្យតែមួយ ដូចជាពាក្យ សាលា រទេះ អង្ករ អង្គុយ ។ល។ ក្នុងភាសាខ្មែរមានពាក្យបែបយ៉ាងនេះច្រើនណាស់ ពាក្យខ្លះសរសេររៀងព្យាង្គ ដូចក្នុងពាក្យ សាលា រទេះ ។ ពាក្យខ្លះសរសេរត្រួតព្យាង្គ ដូចក្នុងពាក្យ អង្ករ អង្គុយ ។ ឯនឹងត្រួតព្យាង្គនេះ មានក្បួនបញ្ញត្តឲ្យត្រួត គឺឲ្យត្រួតតាមវគ្គនៃព្យញ្ជនៈរៀងគ្នា គឺថាក្នុងមួយវគ្គ ៗ មានព្យញ្ជនៈ ៥ តួ ហើយបើព្យាង្គក្រោយតាំងផ្ដើមឡើងនឹងអក្សរក្នុងវគ្គ ត្រូវយកជើងអក្សរនេះផ្សំត្រួតពីក្រោមព្យញ្ជនៈ ទី ៥ នៃវគ្គនោះឯង ឯសញ្ញាស្រៈ ដែលនៅពីលើ ឬពីមុខ ពីក្រោយតួព្យញ្ជនៈខាងលើ គឺផ្សំនឹងជើងព្យញ្ជនៈខាងក្រោម ។ មួយទៀត បើព្យាង្គក្រោយតាំងផ្ដើមនឹងអក្សរដែលប្រើបានជាសំឡេងពីរ គឺ ង ញ ន ម យ រ ល វ នោះសំឡេងវាតែងតែឮលតាមព្យញ្ជនៈដើមព្យាង្គមុន ឧបមាដូចក្នុងពាក្យ សាលា (មិនបាច់សំឡាប់ ល ទេ វាឮលសំឡេងទៅតាម ស ស្រាប់ហើយ ។ ចង្រៃ រ ឮលសំឡេងតាម ច ស្រាប់ហើយ) លើកតែកាលណាព្យាង្គដើមតាំងផ្ដើមនឹងអក្សរ អ នោះសំឡេងនៅដូចដើម ឧបមាដូចក្នុងពាក្យ អន្ទ្រី អន្ទង់ អន្ទុង អន្ទក់ អន្ទ្រែត អន្ទ្រែង អន្ទ្រើង អន្ទ្រែក ។ល។

វគ្គ ង្ក ង្ខ ង្គ ង្ឃ ង

បើព្យាង្គ ង ក្រោយតាំងផ្ដើមនឹងអក្សរ ក ខ គ ឃ នោះ ត្រូវយកជើងអក្សរទាំងនេះ ដាក់ពីក្រោម ង ។

បង្កា បង្ខួត បង្កេះ បង្កើះ បង្កោម បង្ខួម កង្កែប បង្ខិ បង្ខូប បង្ខាត សង្ខេប ហ្វាយបង្គំ បង្គាប់ បង្គោល អង្គុយ បង្គុយ សង្ឃឹម ។

វគ្គ ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ ។

> បើព្យាង្គក្រោយតាំងផ្ដើមនឹងអក្សរ ច ឆ ជ ឈ នោះ ត្រូវយកជើងអក្សរទាំងនេះដាក់ពីក្រោម ញ ។

កញ្ចប់ បញ្ចុះ ចិញ្ចឹម ចិញ្ចើម ចិញ្ចាច បញ្ចូល បញ្ចុះ បញ្ចោរ បញ្ចៀប បញ្ចើ កញ្ច្រែង កញ្ជ្រោង បញ្ឆោត បញ្ជើ បញ្ជាក់ ជញ្ជាំង ចិញ្ចៀន កញ្ជ្រឹល បញ្ឈរ បញ្ឈប់ សញ្ញា បញ្ញើ ។

វគ្គ ដ្ដ ឋ្ឋ ឌ្ឌ ឍ ណ ។

> បើព្យាង្គក្រោយតាំងផ្ដើមនឹងអក្សរ ដ ឋ ឌ ឍ (មាន ដ ជាដើម) នោះ ត្រូវយកជើងអក្សរទាំងនេះដាក់ពីក្រោម ណ ។

កណ្ដាល កណ្ដុរ អណ្ដាត អណ្ដូង អណ្ដើក អណ្ដែត រណ្ដៅ សណ្ដែកបណ្ដុះ ដណ្ដឹង បណ្ដឹង សណ្ដោង ។

វគ្គ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

បើព្យាង្គក្រោយតាំងផ្ដើមនឹងអក្សរ ត្ត ថ្ថ ទ្ទ ធ្ធ នោះ ត្រូវយកជើងអក្សរទាំងនេះដាក់ពីក្រោម ន ។

ប៉ុន្តែ បន្តិចបន្តួច បន្ថែម បន្ថយ បន្តើត កន្ទុយ កន្ទេល បន្ទាត់ បន្ទាប បន្ទាយ សន្ធឹង សន្ធាប់ ។

វគ្គ ប្ប ផ្ផ ព្ព ភ្ភ ម្ម

បើព្យាង្គក្រោយតាំងផ្ដើមនឹងអក្សរ ប ផ ព ភ នោះ ត្រូវយកជើងអក្សរទាំងនេះដាក់ពីក្រោម ម ។ តែបើដាក់ជើងអក្សរពីក្រោម ម មិនត្រូវដំលើព្យាង្គមុខទេ ពីព្រោះ ម ជាជំនួសស្រាប់ហើយ ។

ដើម្បី សម្បើម=សំបើម បម្បាំង=បំបាំង ផ្ទះសម្បែង=ផ្ទះសំបែង ដម្បូល=ដំបូល អម្ពៅ=អំពៅ សម្ពត់=សំពត់

# ក្រៅវគ្គ យ្យ ្រ ល្ល ្វ ស្ស ហ្ហ អ្អ

ពួកនេះ ដាក់ពីក្រោមតួអក្សរចុងវគ្គណាក៏បាន តាមសំដីផ្ទួលទៅ ប៉ុន្តែរឿយៗ ច្រើនតែទៅនៅក្រោម ង ន ម ។

បង្រៃ ផង្រុក បង្រៀន ពន្យល់ ទន្សាយ សន្សើម



ទន្សាយ

សន្សឹម សន្សំ ទន្លាប់ បន្លា បន្លែ ពន្លឺ សម្លាប់ = សំឡាប់ ទម្លាប់ = ទំឈាប់ កម្លោះ = ឈោះ? កំឡោះ សម្រាប់ = សំរាប់ សម្រេប = សំរេប កង្វេរ បង្វិល បង្ហាត់ បង្ហួរ បង្ហិន ដង្ហែ បង្អង់ បង្អែម បង្អាប់ បង្អែក ។

## ការហាត់

ឲ្យដាក់ឲ្យត្រឹមត្រូវតាមសំដាប់អស់ទាំងពាក្យខាងក្រោយនេះ ៖

| | | |
|---|---|---|
| បងកើត = បង្កើត | បងអែរ = បង្អែរ | បងគោល = បង្គោល |
| បងខាំង = បង្ខាំង | កនបោរ = កន្បោរ | បងគង = បង្គង |
| បងកៀង = បង្កៀង | សនសើម = សន្សើម | បងកួយ = បង្កួយ |
| បញបេញ = បញ្ចេញ | បនទុះ = បន្ទុះ | បងគី = បង្គី |
| បងហើយ = បង្ហើយ | កណដៀរ = កណ្ដៀរ | បងគា = បង្គា |
| ពនលក = ពន្លក | បងហាត់ = បង្ហាត់ | បងគាប់ = បង្គាប់ |
| បនទប់ = បន្ទប់ | បងអើល = បង្អើល | បងគួរ = បង្គួរ |
| កនលែង = កន្លែង | កនទ្បះ = កន្ទ្បះ | បងវែ = បង្វែ |
| កណដាល = កណ្ដាល | កនទ្បាត = កន្លាត | ផងរុក = ផង្រុក |
| កណដុរ = កណ្ដុរ | កនទ្បើត = កន្លើត | ផណដឹង = ផណ្ដឹង |
| កណដាប = កណ្ដាប | កនទ្បង = កន្លង | ផណដើម = ផណ្ដើម |
| កណដឹង = កណ្ដឹង | គនលង = គន្លង | ទនលាប់ = ទន្លាប់ |
| កណដៀរ = កណ្ដៀរ | គនលឹះ = គន្លឹះ | ទនលេ = ទន្លេ |



កន្ត្រៃ



កង្កែប



សង្កើច



សន្ទូច

មេរៀនទី ២៩

សញ្ញាផ្សេង ៗ សំរាប់ប្រើក្នុងពាក្យខ្លះ

ហើយនឹងអក្ខរៈខ្លះ លើសពីត្រូវប្រកប :

៏ សញ្ញានេះឈ្មោះ លេខប្រាំបី ឬ លេខអស្ដា

សម្រាប់ប្រើដាក់លើ ក ហើយនឹង ដ ជាបុរាណធក់ទី

ដូចជាពាក្យថា ក៏បាន ក៏ទៅដែរ ដ៏មានគុណ ដ៏ មាន

បុណ្យ ដ៏ ប្រសើរ ។ ល ។

៍ សញ្ញានេះឈ្មោះ បដិសេធ ឬ ទណ្ឌឃាដ

សម្រាប់ដាក់លើព្យញ្ជនៈណា ដែលលើសពីត្រូវប្រកបពាក្យ

ដើម្បីកុំឲ្យបេញសំដីបាន គឺបដិសេធចោល ។ ឯពាក្យដែល

មានបែបនេះ ច្រើនតែកំណើតពីបាលី ឬសំស្ក្រឹតឬពីភាសាដទៃ

ដូចជាពាក្យ ប្រយោជន៍ ភាជន៍ យោជន៍ ខ្ទមបន្ទន៍ ។ ល ។

៧ សញ្ញានេះឈ្មោះ *លេខទោ* គឺលេខ *ពីរ* ក្លាយសម្រាប់ផ្ទួនពាក្យ ដូចក្នុងពាក្យ តូចៗ បន្តិចៗ តិចៗ ម្ដងៗ ។ ល ។

៌ សញ្ញានេះឈ្មោះ *របាទ* គឺអក្សរ *រ* ក្លាយសម្រាប់ដាក់លើពាក្យខ្លះ កំណើតពីសំស្ក្រឹត ដើម្បីឲ្យញ័រអណ្ដាត ហើយត្រូវចំណាំថា បើមានពាក្យណាសរសេរបែបនេះ អក្សរប្រកបខាងក្រោយ ស្ទើរតែចេញសំដីមិនរួច ដូចក្នុងពាក្យ ពណ៌ ទិសបូព៌ បរិបូណ៌ ។ ល ។

៨ សញ្ញានេះឈ្មោះ *សំយោគសញ្ញា* សម្រាប់ប្រើនឹងពាក្យមកពីបាលី ហើយនឹងពាក្យខ្លះដែលត្រូវសរសេរមាន "ទាញយារ" នឹងសង្កត់ផង ដូចក្នុងពាក្យ វិន័យ ជ័យ ភ័យ សម័យ វិនិច្ឆ័យ នង្គ័ល (នង្គាល់) ញ័រ (ញារ់) ជ័រ (ជារ់) ទំព័រ (ទំពារ់) ។ ល ។

ៈ សញ្ញានេះឈ្មោះ វិ ស ជ៌ នី ឬ រះមុខ (បានឃើញ
រួចហើយ) សម្រាប់ប្រើដាក់មុខជិតខ្យល់ ហ សំដីដាច់
ដូចក្នុងពាក្យ នេះ នោះ សេះ រទេះ សង្គ្រោះ បំពោះ ។ ល ។

មួយទៀត មានពាក្យជាច្រើនយកអក្សរលើសពីអក្សរត្រូវប្រកប ហើយប្រើតែជើងនៅក្រោមតួប្រកប ប៉ុន្តែមិនជាឥតប្រយោជន៍ទេ នាំឲ្យសំដីដាច់ដែរ តែក្នុងការមើល ត្រូវប្រកបតែនឹងតួព្យញ្ជនៈលើក៏បានហើយ ។ ឯពាក្យសរសេរបែបនេះច្រើនតែកំណើតពីបាលី ឬសំស្រ្កឹត ឬពីភាសាដទៃ ឧបមាដូចជាពាក្យ ចិត្ត ខែចេត្រ ខេត្ត ថ្ងៃសុក្រ មនុស្ស សិស្ស ពេទ្យ រាស្រ្ត បុណ្យ ភូមិសាស្រ្ត វត្ត (វាត់) អារក្ស (អារាក់) យក្ស (យាក់) ព្រះភក្ត្រ ទ្រព្យ (ទ្រាព់) សម្បត្តិ (សម្បាត់) បញ្ញត្តិ (បញ្ញាត់) ។ល។

## ១.– ខ្ញុំទៅសាលារៀន

ខ្ញុំអាយុប្រាំពីរឆ្នាំ ខ្ញុំធំហើយ ខ្ញុំមិនលេងឥតគំនិតដូចកាលខ្ញុំនៅពីតូចទៀតឡើយ ។ ខ្ញុំទៅសាលារៀន ខ្ញុំរៀនមើល រៀនសរសេរ រៀនធ្វើលេខ រៀនគូរហើយនឹងរៀនបំណេះឯទៀតច្រើនផង ។ ខ្ញុំខំរៀនឲ្យបានចេះឆាប់ ឲ្យបានអក្សរល្អ ហើយនឹងនិយាយត្រឹមត្រូវផង ឲ្យគ្រូខ្ញុំនឹងឪពុកម្ដាយខ្ញុំសប្បាយចិត្ត ។

---

ពាក្យពន្យល់: គំនិត = គឺគិតល្អអាក្រក់ខុសត្រូវ ។ បំណេះ= ការដែលរៀនឲ្យចេះដឹង ។

ពាក្យសួរ: អ្នកអាយុប៉ុន្មាន? ។ អ្នកមករៀនប៉ុន្មានឆ្នាំហើយ? ។ អ្នករៀនអ្វីខ្លះ? ។ អ្នករៀនយ៉ាងដូចម្ដេច? ។

អក្សរផ្ចង់: វាខំរៀន វាសរសេរអក្សរល្អ ។

## ២.– រៀនមើលសៀវភៅ

គ្រូបង្គាប់ ឱ្យមើលសៀវភៅ ។ ឱ្យក្រោកឡើងកាន់សៀវភៅនៅដៃទាំងសងខាង ដាក់បំងាយល្មមនឹងភ្នែកមើល ប៉ុន្តែមិនឱ្យបាំងមុខវាទេ ។ ឱ្យ ឈរត្រង់ខ្លួនមិនងេកងោកក្បាល ។ វាមើលសៀវភៅ វាមើលមួយ ៗ ជាច្បាស់ ៗ មួយម៉ាត់ ៗ ។ យើងនៅស្ងៀមស្តាប់វាមើល ហើយយើងយល់សេចក្តីដែលវាមើលនោះ ។ លុះមើលចប់ហើយ គ្រូប្រាប់ឱ្យឱ្យអង្គុយទៅវិញ ។

livre · yeux · figure · debout · s'asseoir

—·—

ពាក្យពន្យល់: សងខាង= ទាំងពីរខាង គឺខាងស្តាំ ខាងឆ្វេង ។

ងេកងោក = គឺងាកចុះងាកឡើង ទៅខាងនេះម្តង ទៅខាងនោះម្តង ។

អក្សរផ្ចង់: ត្រូវមើលមួយៗ ជាឱ្យច្បាស់ៗ ។

## ៣.- ប្រដាប់ប្រដារបស់កូនសិស្ស

កូនសិស្សរៀនមើលទន្ទេញក្នុងសៀវភៅមើល រៀនសរសេរក្នុងសៀវភៅសរសេរ ។ ត្រូវមានដងប៉ាកកា ស្លាបប៉ាកកា ទឹកខ្មៅ ។ ដើម្បីនឹងគូសបន្ទាត់ ឬគូរគំនូរលើក្រដាស ត្រូវមានបន្ទាត់ហើយនឹងខ្មៅដៃ ។



ត្រូវមានក្រដាសផ្តិតមួយសម្រាប់ផ្តិតអក្សរ ឲ្យស្ងួតឆាប់ ។ ត្រូវមានជ័រលុបមួយសម្រាប់លុបអក្សរ ដែលសរសេរខុស ។ ត្រូវមានដីសសម្រាប់សរសេរលើក្តារខៀន ហើយនឹងក្តារថ្មសម្រាប់គិតលេខ ។

ក្មេងដែលមករៀនឯសាលា ត្រូវមានរបស់ទាំងអស់នេះ ត្រូវរក្សាទុកឲ្យគង់កុំឲ្យបាត់ កុំឲ្យឪពុកម្តាយចាយប្រាក់ទិញទៀត ។

ពាក្យពន្យល់ : ក្រដាសផ្តិត = ក្រដាសក្រាស់ជាងក្រដាសសរសេរ ហើយស្រូបទឹកខ្មៅ ។ ជ័រលុប = របស់ធ្វើនឹងជ័រ សម្រាប់លុបអក្សរខុស ។

ពាក្យសួរ : អ្វីខ្លះដែលជាប្រដាប់ប្រដារបស់កូនសិស្ស ។ សៀវភៅសរសេរ សៀវភៅមើល បន្ទាត់ ខ្មៅដៃ ក្តារឆ្នួនសម្រាប់ធ្វើអ្វី ? ត្រូវរក្សារបស់នោះឲ្យគង់ឬទេ ? ហេតុអ្វី ? ។

អក្សរផ្ចង់ : កូនសិស្សល្អថែរក្សារបស់ឲ្យគង់ ។

## ៤- សាលារៀននៅភូមិខ្ញុំ

សាលារៀននៅភូមិខ្ញុំមានកន្លែងរៀនបី ។ ក្នុងកន្លែងរៀនមួយៗ មានគ្រូម្នាក់ នឹងសិស្សច្រើន ។ ថ្នាក់កុមារដ្ឋានដែលខ្ញុំរៀននៅខាងស្តាំជិតទ្វារដែលចូលទៅ ។

សាលារៀននោះសង់នៅទីដីមួយធំ ។ នៅមុខសាលារៀន មានដើមឈើជាលំអ ហើយនឹងសួនផ្កាមួយ ។ នៅខាងក្រោយ មានទីធ្លាធំមួយ ដែលយើងរៀនវិជ្ជាហាត់ប្រាណ ហើយនឹងលេងក្នុងវេលាឈប់សំរាករៀន ។

ពាក្យពន្យល់ : កុមារដ្ឋាន=ថ្នាក់ក្មេងតូចៗ ដែលទើបនឹងចូលរៀនៗ ឈើជាលំអ= ឈើសម្រាប់ឲ្យល្អមើល ។

ពាក្យសួរ : សាលារៀននៅភូមិអ្នក មានកន្លែងរៀនប៉ុន្មាន? អ្នករៀននៅថ្នាក់ណា ? មានអ្វីនៅជុំវិញសាលាអ្នក ? ។

អក្សរផ្ចង់ : ក្នុងកន្លែងរៀនមួយ ៗ មានគ្រូម្នាក់ នឹងសិស្សច្រើន ។

# ៥ _ កូនសិស្សល្អ

កែវឧស្សាហ៍រៀនណាស់ វាចាំមេរៀនវាទាំងអស់ ហើយវាធ្វើកិច្ចការវាល្អផង នៅក្នុងកន្លែងរៀន វាប្រុងប្រយ័ត្ន ហើយមានកិរិយាសុភាពល្អផង ។ វាបេះគួរសមនឹងគ្រូ ចិត្តល្អនឹងក្មេងដទៃ ហើយស្លូតត្រង់ ចិត្តធ្ងន់ ក្រខឹងផង ។ គេស្រឡាញ់វាទាំងអស់គ្នា ។ កែវជាកូនសិស្សល្អ ខ្ញុំខំយកដំរាប់វា ។



ពាក្យពន្យល់ : មេរៀន = គឺការដែលត្រូវដាក់ឲ្យរៀន ។ កិច្ចការ = រឿងរៀនដែលត្រូវដាក់ឲ្យធ្វើ ។ សុភាព = ស្លូតបូត (ក្មេងនេះសុភាព គឺក្មេងមិនកាចឫកពាស្លូត) ។ ដទៃ = គឺអ្នកទាំងពួង ។ ដំរាប់ = ធ្វើតាម ធ្វើឲ្យដូច ធ្វើត្រាប់ ។

ពាក្យសួរ: តើវាជាក្មេងដូចម្ដេច? ៗ វារៀនដូចម្ដេច? ៗ ហេតុអ្វីបានជាគេស្រឡាញ់វា? ៗ អ្នកចង់ធ្វើដូចវាឬទេ? ៗ

អក្សរផ្ចង់: ត្រូវខំស្វាហាប់រៀន ហើយប្រព្រឹត្តកិរិយាសុភាព ។

## ៦ - កូនសិស្សអាក្រក់

សួនមកសាលារៀនរាល់ថ្ងៃ ប៉ុន្តែវាគិតតែលេងជាងរៀន វាខ្ជិលណាស់ វាមិនប្រយ័ត្នក្នុងការរៀនសូត្រទេ កិរិយាវា



មិនសុភាពទេ មិនបេះគួរសម ហើយមិនស្អាតផង ។ ហេតុដូច្នេះ គ្រូស្ដីបន្ទោសវាជារឿយ ៗ ។ មួយទៀតសួនចិត្តអាក្រក់កាចព្រហើន ចិត្តស្រាលហើយឆាប់ខឹងផង ។ យើងរាល់គ្នាដែលនៅរៀនជាមួយមិនចូលចិត្តនឹងវាទេ ។

ពាក្យពន្យល់: គិតតែលេង = គឺនឹកតែចង់លេង នឹកតែល្បែង ។

ស្ដីបន្ទោស = គឺនិយាយកំហែង ថានឹងធ្វើទោស ។

អក្សរផ្ចង់: មនុស្សខ្ជិលចាំតែរងទុក្ខវេទនា ។

## ៧.– កិច្ចដែលត្រូវប្រណិប័តន៍គ្រូ

នៅសាលាខ្ញុំស្ដាប់គ្រូនិយាយ ខ្ញុំធ្វើការដែលលោកបង្គាប់ឲ្យខ្ញុំធ្វើ ខ្ញុំស្ដាប់បង្គាប់លោក ខ្ញុំសំពះគ្រូពេលាដែលខ្ញុំចូលទៅក្នុងកន្លែងរៀន ហើយនឹងវេលាមុនដែលខ្ញុំត្រឡប់មកផ្ទះវិញ ។ ខ្ញុំសំពះគោរពប្រណិប័តន៍លោកទៀត វេលាដែលជួបប្រទះនឹងលោកនៅផ្លូវ ឬនៅទីកន្លែងណាមួយ ។

ខ្ញុំស្រឡាញ់ ហើយកោតខ្លាចគ្រូខ្ញុំ ដូចជាខ្ញុំស្រឡាញ់ ហើយកោតខ្លាចឪពុកម្ដាយខ្ញុំដែរ ។

ពាក្យពន្យល់ ៖ គោរពប្រណិប័តន៍ = គឺសំពះដោយគោរពខ្លាច ។
ប្រតិបត្តិ ឬ បដិបត្តិ = គឺធ្វើតាម ។

រៀនពាក្យ ៖ ស្តាប់គ្រូនិយាយ ។ ធ្វើតាមបង្គាប់ ។ ត្រឡប់មកផ្ទះវិញ ។

អក្សរផ្ចង់ ៖ យើងត្រូវស្រឡាញ់ ហើយគោរពខ្លាចគ្រូយើង ។

## ៨ - ខ្លួនមនុស្ស

ខ្លួនមនុស្សមានបីបំណែក គឺក្បាលមួយ ដងខ្លួនមួយ ហើយនឹងដៃជើង ។ នៅលើក្បាលមានសក់ ហើយនៅខាងមុខ មានមុខ ។ ក បន្តក្បាលជាប់នឹងដងខ្លួន ។ ដងខ្លួនមានទ្រូងនៅខាងមុខហើយខាងលើ មានពោះនៅខាងក្រោម មានខ្នងនៅខាងក្រោយ ។ ដៃជើងជាប់ទៅនឹងដងខ្លួន ។

ដៃមួយ ៗ មានដើមដៃ កំភួនដៃ ហើយនឹងគូដៃ ។ គូដៃមានម្រាមប្រាំ ។ ជើងមួយ ៗ មានភ្លៅ ស្មងជើង ហើយនឹងគូជើង ។ ដៃសំរាប់ចាប់កាន់យករបស់ទាំងឡាយ ជើងសំរាប់ដើរ ។ នៅក្នុងខ្លួន មានសាច់ ឈាម សរសៃ ហើយនឹងឆ្អឹង ។

មនុស្សមានត្រចៀក ភ្នែក ច្រមុះ ហើយនឹងមាត់ ។ ត្រចៀកសំរាប់ឮ ភ្នែកសំរាប់មើលឃើញ ច្រមុះសំរាប់ហិតក្លិន មាត់សំរាប់ភ្លក់រសជាតិអាហារ ។

---

**ពាក្យពន្យល់** : ចំណែក = របស់ដែលគេចែកជាច្រើនភាគ ១ ភាគៗ ហៅថា ១ចំណែក ។ ភ្លក់ = គឺស៊ីបន្តិចឲ្យគ្រាន់តែដឹងរសជាតិ ។

**ពាក្យសួរ** : ខ្លួនមនុស្សមានប៉ុន្មានចំណែក? ដងខ្លួនខាងមុខហៅអ្វី? ។

**អក្សរផ្ចង់** : *ត្រចៀកសំរាប់ឮ ភ្នែកសំរាប់ឃើញ ។*

## ៩.– ត្រូវសំអាតខ្លួនជាដរាប

ការសំអាតខ្លួន នាំឲ្យបានសេចក្ដីសុខសប្បាយ ត្រូវងូតទឹក ដុសលាងខ្លួនប្រាណឲ្យស្អាតជាដរាប ។ ត្រូវងូតទឹកស្អាតហើយដុសសាប៊ូផង ។ សេចក្ដីស្មោកគ្រោក បណ្ដាលឲ្យមានរោគ ។ ត្រូវបៀសវាងកុំប្រើសម្លៀកបំពាក់ក្រខ្វក់ ហើយកុំបរិភោគបំណាំអាហារណាដែលមិនស្អាត ។ ដៃត្រូវលាងរឿយ ៗ មុនបរិភោគបាយ ក្រោយបរិភោគ និងក្រោយចាប់កាន់អ៊ីវ៉ាន់ណាដែលមិនស្អាត ។ កុំយកម្រាមដៃប្រឡាក់ប្រឡូសទៅជូតទៅពាល់ភ្នែក វានឹងបណ្ដាលឲ្យឈឺភ្នែក ហើយឲ្យទៅជាខ្វាក់ផងក៏មានដែរ ។

---

ពាក្យពន្យល់ : ប្រាណ = គឺខ្លួន ។ បណ្ដាលឲ្យ = គឺនាំឲ្យ ។ រោគ = គឺជម្ងឺ ។ បរិភោគ = គឺស៊ី ។

ពាក្យសួរ : យើងត្រូវងូតទឹកបែបយ៉ាងដូចម្តេច ដើម្បីឲ្យបានស្អាតខ្លួន ? ។ ពីព្រោះអ្វី បានជាយើងត្រូវលាងដៃ មុនបរិភោគបាយ ? ។ ពីព្រោះអ្វី បានជាយើងមិនត្រូវយកម្រាមដៃទៅជូតភ្នែក ? ។

អក្សរផ្ចង់ : យើងត្រូវងូតតែទឹកស្អាត ហើយដុសសាប៊ូផង ។

## ១០- ត្រូវប្រយ័ត្ននឹងរោគ

ត្រូវកុំឲ្យមនុស្សកើតកមរមាស់នៅជិត ពីព្រោះរោគនេះជាជម្ងឺឆ្លង ។ មានជម្ងឺឆ្លងច្រើនទៀត គឺជម្ងឺអាសន្នរោគ - អុត - មូល - របេង ។ គ្រុនចាញ់ឆ្លងតាមមូសខាំ ។ កាលណាមានជម្ងឺឈឺនៅស្រាល ត្រូវប្រាប់ទៅឲ្យគ្រូពេទ្យមើល ត្រូវចាក់ថ្នាំ ផឹកថ្នាំ លេបថ្នាំ កុំទុកយូរ ខ្លាចក្រែងវាទៅជាធ្ងន់ ។ បើកាលណា មានរបួសកាំបិតមុត ឬឈើមុត ត្រូវលាងនឹងទឹកស្អាត

លាបថ្នាំហើយរុំនឹងសំឡីឲ្យជិត ។ រោគក្អកផ្តាសាយ ឈឺទ្រូង កើតមកអំពីត្រជាក់-សើម ។ បើកាលណាមានជម្ងឺឈឺ ត្រូវមើលខ្លួនឲ្យជា ។

នៅវេលាស្រុកកើតជម្ងឺ ត្រូវប្រយ័ត្នកុំបរិភោគបំណាំផ្តេស-



ផ្តាស ត្រូវផឹកតែទឹកដាំពុះ ត្រូវបោសសំអាតផ្ទះសម្បែង សំរាមត្រូវចាក់ចោលឲ្យឆ្ងាយពីផ្ទះ ហើយដុតភ្លើង ត្រូវចាក់ថ្នាំ ត្រូវជោះអុត ។ ហាមផ្តាច់មិនឲ្យបរិភោគបន្លែស្រស់ ហើយនឹងផ្លែឈើខ្ចី ។

---

ពាក្យពន្យល់ ៖ ជម្ងឺអាសន្នរោគ = គឺជម្ងឺចាប់ឈឺម្តង ៗ ច្រើននាក់ ហើយស្លាប់ឆាប់ណាស់ ដូចជាជម្ងឺចុះក្អួត ជម្ងឺប៉េស្ត ។ របេង = គឺជម្ងឺក្អករ៉ៃ ហើយមានធ្លាក់ឈាមផង ។ របួស = គឺដំបៅដោយកាំបិតមុត ឬឈើមុត ។

ពាក្យសួរ : មានជម្ងឺអ្វីខ្លះ ដែលជាជម្ងឺធ្ងន់? ។ កាលណាយើងឈឺ យើងត្រូវធ្វើដូចម្ដេច? វេលាស្រុកកើតជម្ងឺ យើងត្រូវប្រយ័ត្នដូចម្ដេចខ្លះ? ។

អក្សរផ្ចង់- យើងមិនត្រូវបរិភោគផ្លែឈើខ្ចីទេ ។

## ១១.- ក្រុមញាតិចៅកេត

ក្នុងគ្រួចៅកេត មានមនុស្សច្រើននាក់គឺ ឪពុកម្ដាយវា បងប្រុសវាពីរនាក់ ប្អូនស្រីវាម្នាក់ ហើយនឹងវា ។ ម្ដាយវាក្មេងជាងឪពុកវាបីឆ្នាំ ។ ប្អូនស្រីវាអាយុតិចជាងវាពីរឆ្នាំ ។ ចៅកេតមានបងប្អូនច្រើនទៀត កូនរបស់មានឹងម្ដាយមីងវា ត្រូវជាបងប្អូនជីដូនមួយវា ។



បងប្អូនជីដូនមួយប្រុសវាម្នាក់នៅលីវ គាត់ទើបនឹងដណ្ដឹងប្រពន្ធបានកូនក្រមុំគេម្នាក់ ហើយជិតរៀបការហើយ ។ ជីតាខាងឪពុកចៅកេតស្លាប់តាំងពីយូរហើយ ជីដូនវាមេម៉ាយ

ចាស់ជរាណាស់ហើយ ។ ឯជីដូនជីតាខាងម្ដាយវា នៅរស់ទាំងអស់ ជួនណា គាត់នៅជាមួយនឹងកូនប្រុសស្រីគាត់ ជួនកាល គាត់នៅជាមួយនឹងចៅប្រុសគាត់ម្នាក់ ដែលទើបនឹងមានប្រពន្ធ ។

---

ពាក្យពន្យល់– ក្រុម = គឺពួក ។ ញាតិ = គឺបងប្អូនជិតឬឆ្ងាយគ្រប់ទាំងអស់ គេក៏ហៅថា ញាតិសន្តាន ផៅសន្តាន ដែរ ។ គ្រួ = គឺមួយក្រុមមានតែឪពុកម្ដាយ ហើយនឹងកូន ។ លីវ = គឺមិនទាន់មានប្រពន្ធបើជាប្រុស ឬមិនទាន់មានប្ដីបើជាស្រី ។ មេម៉ាយ = គឺស្រីប្ដីស្លាប់ឬលែងគ្នា ។ ជរា = (ជាពាក្យស្ទួនលើពាក្យ ចាស់) គឺបានសេចក្ដីថា ចាស់ ។ កូនប្រសា = គឺកូនគេឯទៀតមកយកកូនខ្លួនធ្វើជាប្រពន្ធ ឬធ្វើជាប្ដី ។

អក្សរផ្ចង់– ខ្ញុំស្រឡាញ់ ហើយគោរពខ្លាច ឪពុកម្ដាយខ្ញុំណាស់ ។

## ១២. – បងប្អូនចៅកេត

ឪពុកចៅកេតត្រូវចិញ្ចឹមក្មួយស្រីកំព្រាម្នាក់ទៀតផង ក្មួយនេះមិនទាន់មានប្ដីទេ ។ ប្អូនប្រុសម្ដាយចៅកេតម្នាក់ក៏មិនទាន់មានប្រពន្ធដែរ គាត់នៅកម្លោះហើយគាត់នៅផ្ទះមួយម្នាក់ឯង ។ បងថ្លៃឪពុកចៅកេតម្នាក់ ប្រពន្ធស្លាប់បានពីរឆ្នាំហើយ គាត់ពោះម៉ាយហើយនៅជាមួយនឹងខ្ញុំកំដរបាវព្រាវ ហើយនឹងម្ដាយក្មេកគាត់ ។ ប្អូនថ្លៃឪពុកចៅកេតម្នាក់ទើបនឹងលែងប្រពន្ធក៏នៅពោះម៉ាយដែរ ។

ចៅកេតស្រឡាញ់កោតខ្លាចស្ដាប់បង្គាប់ ហើយដឹងគុណជីដូនជីតាវាណាស់ ពីព្រោះវាដឹងថាគាត់បង្កើតហើយចិញ្ចឹមបីបាច់រក្សាឪពុកម្ដាយវាៗហៅ យាយ តា ។ បងប្រុសបង្កើតម្នាក់របស់ជីតាចៅកេតៗ មិនស្គាល់ទេ ពីព្រោះគាត់អនិច្ចកម្មមុនវាកើត ។ មនុស្សទាំងអស់ក្នុងវង្សត្រកូលចៅកេតរាប់អានគ្នាហើយជួយគ្នាណាស់ ។

ពាក្យពន្យល់ ៖ កំព្រា = គឺឪពុកឬម្ដាយស្លាប់ពេលឬស្លាប់ទាំងពីរនាក់ ។ បងថ្លៃ = គឺបងខាងប្រពន្ធឬខាងប្ដី ។ ពោះម៉ាយ = គឺប្រុសប្រពន្ធស្លាប់ប្ដីលែងគ្នា ។ ខ្ញុំកំដរបាវព្រាវ = (ជាពាក្យស្ងួនលើគ្នា) គឺអ្នកបំរើ ។ ម្ដាយក្មេក = គឺម្ដាយខាងប្រពន្ធ ឬខាងប្ដី ។ បីប៉ាច់ក្មេក (ជាពាក្យស្ងួនលើគ្នា) = គឺថៃក្មេក ។ បងបង្កើត = គឺបងកើតមកអំពីឪពុកម្ដាយជាមួយគ្នា ។ អនិច្ចកម្ម (ជាពាក្យខ្ពស់) = គឺជាស្លាប់ ។ វង្សត្រកូល = គឺក្រុមញាតិពូជជាមួយគ្នា ។

អក្សរផ្ចង់ ៖ មនុស្សទាំងអស់ក្នុងវង្សត្រកូល ហៅកេតស្រឡាញ់រាប់អានគ្នាណាស់ ។

# ១៣.— ស្រឡាញ់បងប្អូន

កាលពីដើម មានខ្មែរម្នាក់ឈ្មោះប្រាក់ ជំពាក់បំណុលគេម្ភៃណែន រកសងគេមិនបាន ទៅលក់ខ្លួននៅជាខ្ញុំព្រះអង្គម្ចាស់មួយព្រះអង្គ ។ ប្រាក់ជាមនុស្សឧស្សាហ៍ហើយប្រសប់ផង ខំធ្វៀតធ្វើការបានតែបីឆ្នាំ រកបានប្រាក់ម្ភៃណែនដែលជំពាក់គេនោះ ។ មុនដំបូង ប្រាក់គិតនឹងលោះខ្លួនគាត់ឲ្យរួចពីខ្ញុំគេ ប៉ុន្តែដល់ដឹងថា ប្អូននៅជាខ្ញុំគេដូចគាត់ដែរ គាត់ក៏យកប្រាក់ទាំងអស់ទៅលោះប្អូនគាត់ ។

ដល់ព្រះអង្គម្ចាស់ ទ្រង់បានជ្រាបដូច្នោះ ទ្រង់មានព្រះបន្ទូលថា ឯងចិត្តល្អនឹងប្អូនឯង អញឲ្យឯងរួចជាអ្នកជា ទៅរកប្អូនឯងចុះ ហើយនៅជាមួយគ្នាឲ្យសុខសប្បាយ ។

បងប្អូនប្រុសក្តី ស្រីក្តីត្រូវស្រឡាញ់គ្នាជាពរាប ។

ពាក្យពន្យល់ – បំណុល = (មកពីពាក្យថា បុល) ប្រែថា ជំពាក់គេ ។ ណែន = គឺប្រាក់ដែលស្រុកខ្មែរយើងចាយពីដើម គេធ្វើកងប៉ែហែលស្លឹកជ្រៃ ទម្ងន់ស្មើនឹងសាច់ប្រាក់ ១៦ រៀល ។ ប្រសប់ = គឺចេះធ្លាតធ្វើការ ។ លោះខ្លួន = គឺជូនប្រាក់គេឲ្យបានរួចខ្លួនពីខ្ញុំគេ ។ ព្រះអង្គម្ចាស់ = គឺកូនស្ដេច ។ ព្រះបន្ទូល = គឺនិយាយ ។ ជាអ្នកជា = គឺរួចពីខ្ញុំគេ ។ ទ្រង់ = ពាក្យសំរាប់និយាយនឹងស្ដេចដូចជាថា លោក ។

ពាក្យសួរ. ហេតុដូចម្ដេចបានជាប្រាក់លក់ខ្លួនធ្វើជាខ្ញុំគេ? ។ ប្រាក់ជាមនុស្សដូចម្ដេច? ។ ប្រាក់រកប្រាក់បានប៉ុន្មាន? ។ ដល់បានប្រាក់ហើយ ប្រាក់គិតដូចម្ដេច? ។ ព្រះអង្គម្ចាស់មានព្រះបន្ទូលដូចម្ដេច? ។

អក្សរផ្ចង់: បងប្អូនប្រុសក្ដី ស្រីក្ដី ត្រូវស្រឡាញ់គ្នាជាដរាប ។

# ១៤. - ចំណីអាហារខ្មែរ

បាយឆ្អិនហើយ ម្ដាយហើយនឹងបងស្រីចៅមួងដោះដួស ដាក់ចានធំរៀបក្នុងថាសដាក់លើកន្ទេលមួយ ។ នៅជិតខាងនោះ មានទឹកពីរផ្តិល ។ ឪពុកម្ដាយ បងប្អូនប្រុស-ស្រី ហើយនឹងចៅមួងអង្គុយជុំវិញម្ហូបក្ដៅៗនោះ ។ ម្ហូបនោះមានសម្លបន្លែបង់ម្ជូរអម្ពិល-ត្រីងៀតដុត-ត្រីឆ្អើរ-អន្លក់ស្រស់-ទឹកគ្រឿងមួយចាន ហើយនឹងសាច់ជ្រូកសាបអាំងបន្តិច ។

គ្រនោះមិនសូវចូលចិត្តបរិភោគសាច់គោទេ ។ ប្អូនស្រីចៅមួងមិនចេះស៊ីគ្រឿងហារទេ គេធ្វើទឹកជ្រលក់មួយចាន ដែលមានតែទឹកអំបិល ហើយនឹងម្ជូរក្រូចឆ្មារសំរាប់ឲ្យវា ម្ទេសក៏គេមិនដាក់ ម្រេចក៏គេមិនដាក់ ។

ពាក្យពន្យល់ - *ថាស = គឺប្រដាប់កងមូលសំប៉ែតធ្វើនឹងស្ពាន់សំរាប់ដាក់ចានម្ហូបស៊ី ។ បង់ = គឺដាក់គ្រឿងទៅក្នុងសម្ល ។ អន្លក់ = គឺបន្លែដែលគេស៊ីជ្រលក់ក្នុងទឹកគ្រឿង ។ ទឹកគ្រឿង = គឺទឹកជ្រលក់គេដាក់គ្រឿងផ្សេងៗ ។ បរិភោគ = គឺស៊ី ។*

# ១៥. – ចិនស៊ីបាយ

ម្ហូបចិនមានច្រើនមុខ គឺសាច់ជ្រូកកាត់ជាដុំតូចៗ ចៀននឹងខ្លាញ់ ហើយនឹងខ្ទឹម សាច់ជ្រូកខ្វៃ មាន់ ឬទាស្ងោរ ពងទាប្រៃ សាច់ត្រីក ។ ចិនស៊ីបាយនឹងចង្កឹះ ។ កំពុងស៊ីបាយ ចិនផឹកស្រាផង ។ លុះបរិភោគរួចហើយ គេផឹកទឹកតែ ។

អាហារសំខាន់របស់បារាំង គឺនំប៉័ង ។ បារាំងបរិភោគប្រើចានទាប ស្លាបព្រា សម កាំបិតសំរាប់កាត់សាច់ កន្សែងជូតដៃ ហើយផឹកស្រាទំពាំងបាយជូរដាក់ក្នុងកែវ ។ កាលណាបរិភោគរួចហើយ គេអាស្រ័យបង្អែមមានផ្លែឈើឬនំផ្សេងៗ ។

ពាក្យពន្យល់ – ចៀន = គឺចំអិននឹងខ្លាញ់ ។ ជ្រូកខ្វៃ = គឺជ្រូកធ្វើឲ្យក្រៀមមានដាក់គ្រឿងផង ។ សំខាន់ = គឺធំបំផុត ។

អក្សរផ្ចង់: *អាហារសំខាន់របស់ខ្មែរ គឺបាយ ។*

# ១៦.– សំលៀកបំពាក់

សំលៀកបំពាក់ដែលយើងស្លៀកពាក់ ខ្លះធ្វើនឹងអម្បោះ ខ្លះធ្វើនឹងសូត្រឬព្រៃ ។

ខ្មែរប្រុសស្លៀកសំពត់បងក្បិន ហើយពាក់អាវកត្រង់ ។ ស្រីខ្មែរក៏ស្លៀកសំពត់ដែរ ប៉ុន្តែពាក់អាវបំពង់វែង ហើយបង់ក្រមាផង ។ ចាម.ជ្វា ក្លិង្គ ស្លៀកសារុង ៗនោះមានច្រើនពណ៌ ។ យួន ចិន ញារាំង ស្លៀកខោ ។ ខោយួន - ចិនជើងធំទូលាយជាងខោផុះរាំង ។ យួនទាំងប្រុសទាំងស្រីពាក់អាវវែងដាក់ឡេវនៅម្ខាង ហើយប្រុសមានឈ្នួតជូតក្បាលផង ឯស្រីជូតក្បាលនឹងកន្សែងឬបាំងឆត្រឬពាក់មួកជួនធ្វើនឹងស្លឹកចាក ។ ចិនកូនឈ្នួល (គូលី) ស្លៀកខោខ្លីពាក់កណ្តាលភ្លៅហើយលែងខ្លួនទទេ ។ ខោបារាំងជើងតូចបង្អៀត ហើយមានឡេវដាក់ពីខាងមុខ ហើយនឹងហោប៉ៅសងខាងផង ។

ពាក្យពន្យល់ .– ព្រែ = គឺសំពត់ធ្វើពីសូត្រសរសៃឆ្មារល្អ ។ អាវបំពង់វែង = គឺអាវកងមូល ដូចបំពង់ធ្លាក់ដល់ជង្គង់មានដៃវែង ហើយបង្កៀត ។ ឈ្នួត = គឺសំពត់មួយផ្ទាំងតូចដែលគេយកមករុំព័ទ្ធក្បាល ។ ស្លឹកបាក = ស្លឹកដូចស្លឹកត្នោត ប៉ុន្តែតូចជាងស្លឹកត្នោត ។

ពាក្យសួរ: គេយកអ្វីខ្លះមកធ្វើសំលៀកបំពាក់? ។ គេធ្វើដូចម្តេច? ។ ខ្មែរប្រុសស្លៀកដូចម្តេច? ។ ចុះខ្មែរស្រី? ។ ចាម ជ្វា ក្លិង ស្លៀកអ្វី? ។

អក្សរផ្ចង់: យើងត្រូវសំអាតសំលៀកបំពាក់ យើងជាដរាប ។

## ១៧.– សំលៀកបំពាក់ (ត)

នៅស្រុកក្តៅ គេច្រើនប្រើសំលៀកបំពាក់ស ហើយស្តើង ។ ឯស្រុករងា គេប្រើសំលៀកបំពាក់ខ្មៅ ហើយក្រាស់ ហៅថា សាក្លាត ធ្វើពីរោមសត្វចៀម ។

នៅស្រុកខ្មែរយើងសព្វថ្ងៃនេះ ខ្មែរប្រុសមានអ្នករាជការជាដើម ស្លៀកខោ ពាក់អាវបើកក ពាក់មួក ស្រោមជើង ហើយនឹងស្បែកជើង ដូចជាបារាំងដែរ ហើយមានស្រីជាច្រើននៅទីក្រុងពាក់អាវទ្លី មានអាវទ្រនាប់ផង ។ ថ្ងៃបុណ្យស្រីខ្មែរពាក់អាវប៉ាក់ផរ ហើយតែងខ្លួននឹងគ្រឿងមាស គឺខ្សែកកន្លាស់ក ខ្សែខ្លួន ខ្សែដៃ បិញ្ចៀន ទំហូ ការ រយ៉ាដាំត្បូងពេជ្រ ឬត្បូងថ្មផ្សេងៗតាមមាន តាមក្រ ។ ក្មេងស្រីតូចៗ ពាក់កងជើង ស្រីក្រមុំកូនកាត់ចិន សៀតស្មៀតសក់នៅផ្នួងសក់ផង ។

---

ពាក្យពន្យល់: ប៉ាក់ផរ = គឺដាក់ផរផងឲ្យល្អមើលៗ តែងខ្លួន= គឺធ្វើខ្លួនឲ្យល្អ ។ ត្បូងពេជ្រ= គឺត្បូងថ្មល្អបំផុតក្នុងលោក ។ ។ កូនកាត់= គឺកូនកើតមកអំពីឪពុកម្ដាយសាសន៍ខុសគ្នា គឺម្ដាយខ្មែរឪពុកចិន ។

<u>ពាក្យសួរៈ</u> នៅស្រុកក្តៅ គេប្រើសំលៀកបំពាក់ដូចម្តេច? ។ ចុះនៅស្រុករងា? ។ ខ្មែរអ្នករាជការស្លៀកពាក់ដូចម្តេច? ។ វេលាថ្ងៃបុណ្យ ស្រីខ្មែរស្លៀកពាក់ដូចម្តេច? ។

<u>អក្សរផ្ចង់ៈ</u> ថ្ងៃបុណ្យ ខ្ញុំតែងខ្លួននឹងសំលៀកបំពាក់ថ្មី ។

---

## ១៨.— អំពីទីលំនៅ - ផ្ទះខ្មែរ

ខ្មែរនៅផ្ទះសង់លើបន្ទល់ខ្ពស់ពីដី ធ្វើនឹងឈើ ឬនឹងឬស្សី ប្រក់ស្លឹកត្នោត ឬស្បូវ ។ តាមធម្មតា សសរធ្វើនឹងឈើផាប់ រនាបធ្វើនឹងបន្ទះឬស្សីត្បាញ ជញ្ជាំងធ្វើនឹងស្លឹកឬនឹងឬស្សីដែរ។ តាមទំនៀមទំលាប់ខ្មែរមិនធ្វើទ្វារបង្អួចច្រើនទេ មានតែទ្វារចូលមួយហើយនឹងបង្អួចតូចៗពីរបី ។ គេចូលផ្ទះឡើងតាមជណ្តើរ។ នៅក្នុងផ្ទះអ្នកក្រ តុក៏គ្មាន កៅអីក៏គ្មាន ជើងម៉ាក៏គ្មាន ទូក៏គ្មាន

ទូបានក៏គ្មាន ហើយគ្រែក៏គ្មានដែរ ។ គេដេកលើកន្ទេលក្រាលលើរនាប ។ បន្ទប់ទទួលភ្ញៀវនៅល្វែងក្រៅធ្វើជាបន្ទប់ស៊ីបាយផង ។ ប៉ុន្តែអ្នកមានគ្រាន់បើ ហើយនឹងនាម៉ឺនខ្លះមានផ្ទះឈើ ក្រាលក្តារ ប្រក់ក្បឿង ។ អ្នកមានធំខ្លះមានផ្ទះឥដ្ឋពីរជាន់ ហើយមានពិតានផង ។

---

ពាក្យពន្យល់ : ចន្ទល់= គឺឈើបង្គោលសម្រាប់ទល់ពីក្រោម ។ ស្បូវ= គឺស្មៅមួយយ៉ាង ស្លឹកតូចវែងសម្រាប់ប្រក់ផ្ទះ ។ ភ្ញៀវ= គឺមនុស្សមកសួរ ឬមកលេងផ្ទះ ។ ផ្ទះពីរជាន់ = ផ្ទះមានថ្នាក់លើថ្នាក់ក្រោម ។ ពិតាន = គឺធ្វើពីក្តារ ឬពីបាយអបិទពីក្រោមដំបូលកុំឲ្យក្តៅ ។

ពាក្យសួរ : ផ្ទះខ្មែរគេសង់បែបដូចម្តេច ? ។ គេច្រើនតែប្រក់នឹងអ្វី ? ។ គេចូលផ្ទះឡើងតាមអ្វី ? ។ ផ្ទះអ្នកមានធំ គេច្រើនតែធ្វើដូចម្តេច ? ។

អក្សរផ្ចង់ : យើងត្រូវបោសសំអាតផ្ទះរាល់ថ្ងៃ ។

# ១៩ - ភូមិខ្ញុំ

ភូមិខ្ញុំនៅជិតក្រុង មានផ្លូវថ្នល់មួយទៅពីភ្នំពេញកាត់ភូមិនោះ ។ ផ្លូវនោះធំទូលាយក្រាលថ្ម ហើយចាក់កៅស៊ូផង ។ បើទៅភូមិនោះ គេត្រូវចុះពីផ្លូវធំ ហើយដើរតាមផ្លូវជើងមួយទៅ ។ នៅរដូវវស្សា ផ្លូវជើងនេះមានទឹកដក់ជាថ្លុកដុំៗ មានភក់ ហើយមានក្រហេងក្រហូងជាច្រើនអន្លើ ប៉ុន្តែក្នុងរដូវប្រាំង រទេះគោបរទៅបានក្នុងមួយថ្ងៃដល់ភូមិ ។ នៅចិញ្ចើមសងខាងផ្លូវថ្នល់ត្រង់កន្លែងផ្លូវបែកចុះទៅភូមិ មានផ្ទះតៀមចិនលក់ទំនិញពីរបី ។

ផ្ទះទាំងអស់នៅភូមិនោះ សុទ្ធតែសង់លើបង្គោលខ្ពស់ពីដី ហើយប្រក់ស្លឹក មានតែផ្ទះមេឃុំមួយប្រក់ក្បឿង ហើយល្អជាងគេ ។ ផ្ទះទាំងនោះមានរបងបង្គោលឫស្សីព័ទ្ធជុំវិញ នៅក្នុងរបងនោះ មានដើមចេក ដូង ស្លា ខ្នុរ ទៀប ត្របែក ល្មុត មៀន ទទឹម ។ ផ្ទះខ្លះមានក្រោលគោធ្វើនៅកៀនក្បែររបង ទ្រុងជ្រូក ហើយនឹងទ្រុងមាន់ធ្វើនៅក្រោមម្លប់ដើមស្វាយ ។

នៅចុងម្ខាងឆ្ងាយបន្តិច ហើយជិតសាលារៀន មានផ្សារមួយ ដំបូលប្រក់ក្បឿង សសរឈើ បំហា ឥតជញ្ជាំង គឺនៅផ្សារនោះហើយ ដែលអ្នកស្រុកតែងតែនាំទំនិញទៅដាក់លក់ ហើយនឹងទិញជួររាល់ព្រឹក ។

---

## ២១._ ផ្សារនៅភូមិខ្ញុំ

ផ្សារនោះនៅកណ្ដាលភូមិ សង់នៅជិតមាត់ផ្លូវទេះឡាន។ សសរធ្វើនឹងឥដ្ឋបាក់បាយអ ដំបូលប្រក់ក្បឿង ហើយបំហាឥតជញ្ជាំង ទំហំធំល្មម បណ្ដោយប្រវែងប្រហែល ២០ ម៉ែត្រ ទទឹងប្រហែល ១៥ ម៉ែត្រ ។ ក្នុងផ្សារមានចែកជាច្រើនល្វែង ។ ក្នុង



ល្វែងមួយ មានចិនលក់សាច់ជ្រូក ហើយនឹងសាច់គោ ដាក់តុដំរៀបជាជួរ ។ នៅល្វែងមួយទៀត មានស្រីអ្នកលក់ត្រីអង្គុយ

ប្រហោង ដាក់កញ្ជើត្រីពីខាងមុខ មានត្រីរស់ (ត្រីស្រស់) ត្រីងាប់ ត្រីងៀត ត្រីឆ្អើរ អន្លង់ ក្តាមសមុទ្រ បង្កង ។ កន្លែងដាក់សាច់ ហើយនឹងត្រីនេះ គេបោសលាងរាល់ថ្ងៃ ប៉ុន្តែនៅតែធុំក្លិនពុំសូវស្រួល ។ ល្វែងបន្ទាប់ទៀត មានអ្នកលក់ចំណី ដំរៀបដង្ហែគ្នា រួបទើបដល់អ្នកលក់មាន់ទា . ផ្លែឈើហើយនឹងបន្លែគ្រប់មុខគេគរទំនិញលក់លើរាន ។ នៅក្បែរនោះមានពួកអ្នកលក់ថ្នាំកែរោគដំរៀបថ្នាំសំបកឈើ ហើយនឹងឫសឈើចងជាបាច់តូចៗ ដាក់លើកន្ទេលក្រាលនៅដី ។

រាល់ព្រឹក នៅទីផ្សារមានមនុស្សជាច្រើន ដើរទៅដើរមក ប៉ះគ្នាបង្អៀតពិបាកដើរណាស់ ។ អ្នកទិញ ហើយនឹងអ្នកលក់ ជជែកគ្នាអំពីថ្លៃទំនិញឮសូរទ្រហឹង ។

# ២១. - ការអ្នកធ្វើស្រែ

អ្នកស្រែមានការធ្វើគ្រប់រដូវ គ្រប់ពេលវេលា តាំងពីដើមឆ្នាំ រហូតដល់ចុងឆ្នាំ ។ កាលណាចូលក្នុងរដូវវស្សាហើយ មុនដំបូងគេរៀបចំប្រដាប់ប្រដាសំរាប់ធ្វើស្រែ គឺចបនង្គ័ល រនាស់ ហើយកាលណាភ្លៀងធ្លាក់ច្រើនហើយ គេភ្ជួរ-រាស់ថ្នាល រួចគេយកស្រូវពូជដែលគេត្រាំទឹក ហើយដែល



មានប៊ិចពន្លកទៅសាបក្នុងថ្នាលនោះ ។ ខ្មែរភ្ជួរស្រែនឹងនង្គ័លទឹមគោ ឬក្របី ។ លុះដល់សំ-ណាបដុះបានកំពស់ល្មមហើយ គេដកវាយកទៅស្ទូងក្នុងស្រែធំ ។ ការដក-ស្ទូងនេះច្រើនតែស្រីធ្វើ ដល់ស្ទូងរួចហើយគេត្រូវថែរាំសន្ទូងទៀតទាល់តែស្រូវចេញ គឺដាក់ជី បោចស្មៅ ទប់ទឹក មើលប្រយ័ត្នកុំឲ្យសត្វស៊ី ។ល។

ពាក្យពន្យល់ ៖ រដូវវស្សា = គឺរដូវភ្លៀង ។ ថ្នាល = គឺស្រែតូច ៗ សំរាប់សាបស្រូវ ។ សំណាប = គឺស្រូវទើបនឹងដុះនៅក្នុងថ្នាល ។ ស្ទូង = គឺស្រូវដែលគេស្ទូងនៅក្នុងស្រែ ។ ស្រូវបេញ = គឺស្រូវតាំងមានផ្លែ ។

ពាក្យសួរ ៖ កាលណាចូលក្នុងរដូវវស្សាហើយ អ្នកស្រែត្រូវរៀបចំអ្វី ? ។ កាលណាភ្លៀងធ្លាក់ច្រើនហើយ អ្នកស្រែត្រូវធ្វើអ្វី ? ។

អក្សរផ្ចង់ ៖ ក្នុងរដូវវស្សា រាល់ពេល មានមនុស្សធ្វើការក្នុងស្រែ ។

## ៦៦. - ការអ្នកធ្វើស្រែ (ត)

បើកាលណារាំងភ្លៀងហើយ គ្មានទឹកក្នុងស្រែ គេបាចទឹកពីប្អូក-ត្រពាំង ឬពីប្រឡាយទឹកជិតខាងបញ្ចូលស្រែ គេបាចទឹកនឹងស្នាប ដូនណា គេជីករងះកាត់ភ្លឺស្រែបង្ហូរទឹកដាក់ស្រែ ។

ដល់កាលណាស្រូវទុំហើយ គេច្រូតស្រូវនោះនឹងកណ្ដៀវ គេ



កណ្ដៀវ

កាត់ពាក់កណ្ដាលដើម បង ជាកណ្ដាប់ រួចគេជញ្ជូនទៅ គរក្នុងលានមួយ រួចហើយ គេបោក ឬបែនកណ្ដាប់នោះ ឲ្យគ្រាប់ស្រូវជ្រុះចេញពីគួរ ។ ឯចម្បើងគេគរទុកឲ្យគោ ឬក្របីស៊ីក្នុងរដូវប្រាំង ឬទុកប្រក់ខ្ទម ។

---

ពាក្យពន្យល់ : ស្នាច = គឺប្រដាប់ធ្វើពីឈើលុងកណ្ដាលដូចស្ទូក មានដងសម្រាប់កាន់បាចទឹក គេព្យួរនឹងឈើជ្រាងបី ។ កណ្ដាប់ = គឺបាច់ស្រូវ ។ លាន = គឺដីដែលគេធ្វើឲ្យរលីងសំរាប់បោកស្រូវ ។ បោកស្រូវ = គឺយកកណ្ដាប់ទៅបោកនឹងក្ដារបញ្ឈររាងទេរឲ្យជ្រុះគ្រាប់ស្រូវ ។ បែនស្រូវ = គឺយកកណ្ដាប់ទៅជាន់ឈ្លីនឹងជើងឲ្យជ្រុះគ្រាប់ស្រូវ ។

គួរស្រូវ = គឺចង្កោមផ្លែស្រូវ ។ ចំបើង = គឺដើមស្រូវដែលជ្រុះគ្រាប់អស់ហើយ ។ រដូវប្រាំង = គឺរដូវគ្មានភ្លៀងហើយក្ដៅផង ។

ពាក្យសួរ: បើគ្មានទឹកក្នុងស្រែ គេត្រូវធ្វើដូចម្ដេច? ។ គេបាចទឹកពីឯណាមកដាក់? ។ គេបាចទឹកនឹងអ្វី? ។

អក្សរផ្ចង់– គេច្រូតស្រូវនឹងកណ្ដៀវ ។

## ២៣ – ស្រូវ

ដំណាំធំបំផុតនៅប្រទេសកម្ពុជាគឺស្រូវ គេដាំស្រូវសឹងតែគ្រប់កន្លែង ហើយច្រើនក្នុងខេត្តកំពង់ធំ តាកែវ កំពត ហើយនឹងស្វាយរៀង ។ តាមធម្មតា គេដាំស្រូវបានតែមួយដងក្នុងមួយឆ្នាំ គេធ្វើស្រែនៅរដូវវស្សា គឺរដូវភ្លៀង គេហៅថា ស្រូវវស្សា ប៉ុន្តែនៅតំបន់ខ្លះជិតបឹង ឬព្រែក-ស្ទឹង ដែលទឹករីងមិនដាច់ គេក៏ធ្វើស្រែនៅរដូវប្រាំងដែរ គេហៅថា ស្រែប្រាំង ។ ស្រូវមាន

ច្រើនបែប គឺស្រូវខ្សាយសម្រាប់ដាំបាយបរិភោគ ស្រូវដំណើបសំរាប់ធ្វើនំ ស្រូវស្រាល ស្រូវធ្ងន់ ស្រូវឡើងទឹកដែលគេដាំក្នុងបឹងត្រពាំង ឬនៅទីដីទំនាបដែលទឹកជំនន់លិច វាលូតឡើងតាមទឹក ។

ពាក្យពន្យល់ : ប្រទេសកម្ពុជា = គឺស្រុកខ្មែរ ។ តំបន់ = គឺកន្លែង ។ ស្រូវដំណើប = គឺស្រូវបាយទន់ហើយស្អិត ។ ស្រូវស្រាល = គឺស្រូវឆាប់ផ្លែ ។ ស្រូវធ្ងន់ = គឺស្រូវក្រផ្លែ ។

ពាក្យសួរ : ដំណាំអ្វីដែលជាធំបំផុត នៅក្នុងស្រុកខ្មែរ ? ។ គេដាំស្រូវច្រើន នៅកន្លែងណាខ្លះ ? ។ គេធ្វើស្រែ នៅរដូវណា ? ។

អក្សរផ្ចង់ : ស្រូវជាដំណាំធំបំផុត នៅស្រុកខ្មែរ ។

# ៦៤. - អំពីដំណាំ

ក្រៅអំពីស្រូវ អ្នកស្រុកមាត់ទន្លេធំដាំពោត ដំឡូង សណ្ដែក សណ្ដែកដី កប្បាស ត្រី ល្ង ថ្នាំ អំពៅ ។ អ្នកខ្លះមានដាំល្ហុងខ្វៃរផងសំរាប់យកប្រេង ហើយនឹងមន ដើម្បីយកស្លឹកវាឲ្យដង្កូវនាងស៊ី ។ ពោត ដំឡូង ហើយនឹងមើមក្ដួប គេស៊ីជំនួសបាយបាន នៅវេលាស្រុកអត់បាយ ។

ឯដើមឈើស៊ីផ្លែក៏មានច្រើនណាស់ដែរ គឺចេក ដូង ស្វា ខ្នុរ ស្វាយ ល្ហុង ត្របែក ទៀប ម្នាស់ ល្មុត មៀន ទទឹម ក្រូចឆ្មារ ក្រូចពោធិ៍សាត់ ក្រូចថ្លុង ក្រូចឃ្វិច ស្ដី ហើយនឹងត្នោត គេដាំច្រើនក្នុងខេត្តខ្លះ នៅស្រុកស្រែ សំរាប់យកទឹកពីផ្កាវា ធ្វើជាស្ករក៏បាន ផឹកក៏បាន ហើយនឹងយកស្លឹកវាសំរាប់ប្រក់ផ្ទះ ។ នៅគ្រប់ផ្ទះខ្មែរ គេដាំម្លូ ពីព្រោះខ្មែរស៊ីស្លា ប៉ុន្តែគេមិនសូវឃើញ



មានសួនផ្កាទេ ឡើយ ៗ គេឃើញមានតែបំការបន្លែ គេដាំត្រសក់ ឪឡឹក ត្រឡាច ល្ពៅ ស្ពៃ ខ្ទឹម ប៉េងប៉ោះ ត្រប់ ម្ទេស ។

---

ពាក្យសួរ– ក្រៅអំពីស្រូវ នៅស្រុកខ្មែរគេដាំដំណាំអ្វីទៀត ? ។ ដំណាំអ្វីខ្លះដែលគេដាំយកផ្លែ ? ។ ដំណាំអ្វីខ្លះដែលគេដាំយកមើម ? ។ ដំណាំអ្វីខ្លះដែលគេដាំយកគ្រាប់ ? ។ ដំណាំអ្វីខ្លះដែលគេដាំយកស្លឹក ? ។ វេលាស្រុកអត់បាយ គេស៊ីអ្វីជំនួសបាយបាន ? ។ ដើមត្នោតយ៉ាងដូចម្ដេច ? ។ ដើមត្នោតមានប្រយោជន៍អ្វីខ្លះ ? ។

អក្សរផ្ចង់– អំពៅ ហើយនឹងត្នោត គេយកទឹកវាធ្វើស្ករ ។

---

## ២៥_ សត្វស្រុក

គោ ក្របី សេះ ឆ្កែ ឆ្មា ជ្រូក មាន់ ទា ក្ងាន ចៀម ពពែជាសត្វស្រុក សត្វអស់ទាំងនេះ ខ្លះជួយធ្វើការឲ្យយើង ដូចជាខ្ញុំកំដរ គេហៅថា សត្វបំរើ ។

ឆ្មាចាប់កណ្ដុរ ។ ឆ្កែចាំផ្ទះការពារនឹងចោរកុំឲ្យចូលលួចទ្រព្យសម្បត្តិ វាព្រុសហើយវាដេញខាំចោរ ។ ជ្រូកយើងយកសាប់វាបរិភោគ ។ មាន់-ទា យើងយកពងវា ហើយនឹងសាប់វាដែរ ។



គោ-ក្របីសំរាប់ភ្ជួរដី ក្របីមានស្នែងវែង ហើយស្រួច វាចូលចិត្តដេកត្រាំទឹកណាស់ ហើយពូកែហែលទឹកណាស់ផង វាហែលឆ្លងទន្លេពីត្រើយម្ខាងទៅត្រើយម្ខាង ។ សេះសំរាប់ជិះ ហើយនឹងអូសរទេះ ។ ដំរីកំណើតជាសត្វព្រៃ គេទាក់វាយកមកផ្សាំងចិញ្ចឹមធ្វើជាសត្វស្រុក សំរាប់ដឹកនាំរបស់ធ្ងន់ៗវាមានប្រមោយមួយវែងសំរាប់ធ្វើជាដៃ កន្ទុយវាខ្លី ស្បែកវាក្រាស់ ហើយមានរោមតិច ភ្លុកវាលក់បានថ្លៃណាស់ គេយកភ្លុកវាធ្វើកង ដងប៉ាកកា កន្ទុយបារី ក្រាសសិតសក់ ប្រអប់ៗល ។

សត្វទាំងអស់នេះមានប្រយោជន៍នឹងយើង ហេតុដូច្នេះយើងត្រូវឲ្យចំណីវាស៊ី ត្រូវថែរក្សាវា ត្រូវកុំវាយធ្វើបាបវាឲ្យសោះ ។

# ២៦.- មេទន្ទេញ



សង្វាតសរសេរ អស់អញ កុំខ្ជិល ទើបបានជាគាប់ សង្វាតសូត្ររៀន ដោយគ្រូប្រញប្ត កុំធ្វើលេលាប់ ដោយចិត្តមាក់ងាយ ។ អាស្សូរមេបា ចិញ្ចឹមរក្សា ពុំឲ្យអន្តរាយ អាចយកមកធ្វើ នឹងគ្រូបាធ្យាយ ហេតុបង់ពណ្ណរាយ ក្នុងនាលោកិយ ។ (ច្បាប់ក្រម)

ពាក្យពន្យល់ៈ *សង្វាត = ឧស្សាហ៍ខំរៀន ។ អស់អញ = គឺស្មោះចំពោះលើខ្លួន ។ លេលាប់ = ធ្វើតាមចិត្ត ធ្វេសប្រហែស ។ ប្រញប្ត (ប្រជ្ញប្ត) = គឺបញ្ញត្តការដែលគេបានសំរេចហើយ ។ មេបា = ម្តាយឪពុក (ពាក្យបុរាណហៅថាមេបា) ។ ពណ្ណរាយ = គឺល្អរុងរឿង ។*

អក្សរផ្ចង់ៈ *អាស្សូរមេបា ចិញ្ចឹមរក្សា ពុំឲ្យអន្តរាយ ។*

## ២៧.– ទំនុកច្រៀង



សារិកាកែវអើយ ស៊ីអីកង ៗ
ស៊ីផ្លែដំបង ប្រចឹកគ្នាលេង ។
ស្លាបវាចាក់ក្បាច់ មាត់វាធ្វើភ្លេង
ប្រចឹកគ្នាលេង លើមែកព្រឹក្សា ។

ពាក្យពន្យល់ៈ សារិកាកែវ = សត្វស្លាប រេះត្រាប់ពាក្យមនុស្ស បើគេយកមកចិញ្ចឹម ។ ប្រចឹក = គឺខាំគ្នាលេងនឹងចំពុះ ។ ព្រឹក្សា = គឺដើមឈើ ។

ពាក្យសួរៈ អ្នកដែលឃើញសារិកាកែវឬទេ? ។ ឃើញឯណា? ។ វាចេះធ្វើអ្វីខ្លះ? ។ ហេតុអ្វី បានជាគេចាប់វាយកមកចិញ្ចឹម? ។ ចិញ្ចឹមសត្វទុកក្នុងទ្រុងដូច្នេះ ជាការល្អឬទេ? ។ ពីព្រោះអ្វី? ។

អក្សរផ្ចង់ៈ ស្លាបវាចាក់ក្បាច់ មាត់វាធ្វើភ្លេង ។

# ២៨. - ប្រដាប់ដឹកនាំអីវ៉ាន់

ចិនប្រសប់ធ្វើជំនួញណាស់ លក់ដូរពូកែណាស់ ។ ខ្មែរមិនធ្លាប់ធ្វើជំនួញទេ មិនសូវហ៊ានធ្វើទេ ខ្លាចខាត គេចូលចិត្តធ្វើស្រែ-ចំការយកផលលក់ឲ្យចិន ។ ការដែលទុកឲ្យចិនធ្វើជំនួញដូច្នេះ ចិនបានចំណេញជាប្រាក់ច្រើនណាស់ ។

ការជំនួញនៅស្រុកខ្មែរ ធ្វើជាមួយនឹងប្រទេសវៀតណាមខាងត្បូង តាមផ្លូវជើងទឹកក៏បាន តាមផ្លូវជើងគោកក៏បាន ។ តាមផ្លូវជើងទឹក គេដឹកនាំទំនិញនឹងកប៉ាល់ ឬនឹងទូកប៉ុកបាយ (ទូកថ្ងៃ) តាមទន្លេមេគុង ទៅដល់ក្រុងព្រៃនគរ រួចមានកប៉ាល់សមុទ្រនាំចេញទៅប្រទេសដទៃទៀត ។

កាលមុនបារាំងសែសចូលមកនៅៗ ប្រទេសកម្ពុជា គ្មានផ្លូវថ្នល់ទេ គេដើរដំណើរតាមផ្លូវជើង គេជិះរទេះគោ ឬជិះទូកអុំ ឬចែវតាមទន្លេ-ស្ទឹង ឬព្រែក ដើរដំណើរយ៉ាងនេះពិបាកណាស់ ហើយយូរផង ។ សព្វថ្ងៃនេះ មានផ្លូវថ្នល់ក្រាលថ្មខ្វាត់ខ្វែង មាន

ស្ពានធ្លងព្រែក ហើយមានរទេះឡានដឹកនាំទំនិញ និងអ្នកដំណើរពីក្រុងមួយទៅក្រុងមួយបានឆាប់រហ័សដូចបិត្ត ហើយមានទាំងផ្លូវរទេះភ្លើងទៀតផង ពីក្រុងភ្នំពេញទៅដល់ព្រំប្រទល់ដែនប្រទេសថៃ ។

## ២៩ _ កូនត្រកូលមួយៗធ្វើការទាំងអស់គ្នា

ឪពុកខ្ញុំ និងបងប្រុសខ្ញុំធ្វើការឯស្រែ ម្ដាយខ្ញុំលក់ដូរឯផ្សារ បងស្រីខ្ញុំធ្វើការឯផ្ទះ គាត់បោសសំអាតផ្ទះ រៀបចំទុកដាក់អីវ៉ាន់



ធ្វើម្ហូបចំណី ប៉ះដេរសំពត់សំលៀកបំពាក់ ។ គេទាំងអស់គ្នាមានមុខការគ្រប់ខ្លួន តែខ្ញុំមួយមិនទាន់បានការប្រយោជន៍អ្វី ប៉ុន្តែខ្ញុំធ្វើការនឹងរៀនសូត្រនេះដែរ ខ្ញុំខំរៀនឲ្យបានជាមនុស្សចេះដឹងមានប្រយោជន៍ទៅមុខទៀត ។

ពាក្យពន្យល់ : *អីវ៉ាន់ = របស់ផ្សេងៗ ។ ប៉ះ = គឺដេរសំពត់មួយបន្ទះបិទកន្លែងណាដែលសំលៀកបំពាក់រហែក ។*

ពាក្យសួរ ៖ ឪពុកអ្នកធ្វើអ្វី ? ។ ម្ដាយអ្នកធ្វើអ្វី ? ។ បងប្រុស ស្រី អ្នកធ្វើអ្វី ? ។ អ្នកធ្វើអ្វី ? ។

អក្សរផ្ចង់ ៖ រាល់គ្នាមានការធ្វើគ្រប់ខ្លួន ។

## ៣០_ ពេលវេលា

ថ្ងៃនេះ ខ្ញុំមិនទៅណាទេ ខ្ញុំនៅផ្ទះ ។ ស្អែក ខ្ញុំមិនទំនេរទេ ខ្ញុំមិននៅផ្ទះទេ ខ្ញុំទៅសួរបងប្អូន ហើយខានស្អែក ខ្ញុំត្រឡប់មកវិញ ។ ពីម្សិលមិញ ចៅកេតវាសរសេរសំបុត្រផ្ញើទៅឪពុកម្ដាយវា ។ ឈ្មោះអ៊ុតទើបនឹងបួលរៀនពីម្សិលមួយថ្ងៃ (ម្សិលម៉្ងៃ) ។ ឈ្មោះម៉ៅទើបនឹងទៅអំមិញ (អម្បាញ់មិញ) ។ ពីព្រឹកមិញ ត្រជាក់ស្រួល ឥឡូវនេះក្ដៅ ។ ព្រឹកនេះយើងឈប់



រៀន ។ ពេលព្រឹក រាល់ថ្ងៃ យើងត្រូវរៀន ពីម៉ោងប្រាំពីរកន្លះដល់ ម៉ោងមួយដណ្ដប់ ហើយពេលរសៀល ពីម៉ោងបីដល់ម៉ោងប្រាំ ល្ងាច ។ រាល់ព្រឹក ខ្ញុំក្រោកពីដេកពីព្រលឹម ប្រញាប់នឹងទៅ សាលារៀន ។ អ្នកត្រូវមករៀនឲ្យទាន់ម៉ោង ។ ថ្ងៃត្រង់ ឪពុកម្ដាយខ្ញុំពិសាបាយ ខ្ញុំក៏ទទួលទានជាមួយនឹងគាត់ដែរ ។ ម៉ោងប៉ុន្មាន អ្នកចេញពីរៀន ។ ដល់ម៉ោងហើយឬនៅ ។ ដល់ម៉ោងហើយ ។ ហួសម៉ោងហើយ ។ ជិតដល់ម៉ោង ហើយ ។ នៅបន្តិចទៀត ។ ម៉ោងប្រាំខ្វះដប់នាទី ។

## ៣១._ យប់ អាទិត្យ ខែ ឆ្នាំ

ឯងមកដល់ពីកាលណា (ពីអង្កាល់) ។ ខ្ញុំបានទើបនឹង មកដល់អំមិញ (អម្បាញ់មិញ) ។ ខ្ញុំបានមកដល់យូរបន្តិច ហើយ ។ ពីយប់មិញ មានភ្លៀងច្រើន ហើយមានខ្យល់ព្យុះផង ។ តាំងពីព្រលប់ដល់កណ្ដាលអធ្រាត្រ ខ្ញុំរងាណាស់ ទទួលទាន

---

ដុំណោកពុំសូវលក់ទេ ឪពុកខំរកសំភារៈមិនបានដែរ ។ ពីខែមុនខំឈឺមួយអាទិត្យ ។ ពីឆ្នាំទៅ មានភ្លៀងតិចណាស់ ។ ឆ្នាំក្រោយប្រហែលមានភ្លៀងច្រើន ។ ថ្ងៃណាអ្នកឈប់រៀន ។ ថ្ងៃនេះថ្ងៃអី ។ ថ្ងៃនេះថ្ងៃអាទិត្យ ។ មួយអាទិត្យ មានប្រាំពីរថ្ងៃ គឺ ថ្ងៃអាទិត្យ-ចន្ទ-អង្គារ-ពុធ-ព្រហស្បតិ៍-សុក្រ-សៅរ៍ ។ ក្នុងមួយឆ្នាំ មាន ១២ ខែ គឺខែមិគសិរ-បុស្ស-មាឃ-ផល្គុន-ចេត្រ-ពិសាខ-ជេស្ឋ-អាសាឍ-ស្រាពណ៍-ភទ្របទ-អស្សុជ-កត្តិក ។ ខ្មែរបែកខែនីមួយ ៗ ជាពីរបំណែក បំណែកខាងដើម គឺខែភ្លឺហៅថា ខ្នើត បំណែកខែងងឹត ហៅថា រនោច គេរាប់ថា ១ កើត ២ កើត . . . រហូតដល់ ១៥ កើត គឺថ្ងៃពេញបូណ៌មី រួច ១ រោច ២ រោច . . . រហូតដល់ ១៤ ឬ ១៥ រោច គឺថ្ងៃខែដាច់ ។ ថ្ងៃ ៨ កើត ថ្ងៃ ៨ រោច ថ្ងៃពេញបូណ៌មី ថ្ងៃខែដាច់ ជាថ្ងៃសីល ។

---

## ៣៦.- វត្ត

វត្តនៅបុងភូមិ មានរបងបង្កោលឈើព័ទ្ធជុំវិញ ។ ព្រះវិហារសាងលើដីទួលធំមួយ រាងបួនជ្រុងទ្រវែង ។ នៅក្នុងវត្តមានកុដិលោកសង្ឃជាច្រើន សង់លើបន្ទល់ខ្ពស់ពីដី ។ នៅកណ្តាលទីធ្លា មុខកុដិលោកគ្រូចៅអធិការ មានព្រះវិហារ ហើយនៅខាងស្តាំ មានសាលាមួយធំសម្រាប់លោកឆាន់ ខាងឆ្វេងមានសាលាមួយទៀត សំរាប់ឧបាសកជើងវត្តមកប្រជុំគ្នាធ្វើបុណ្យ ។ បើចូលទៅក្នុងព្រះវិហារ គេឃើញព្រះពុទ្ធរូបធំមួយព្រះអង្គ ហើយនឹងព្រះពុទ្ធរូបតូចៗ ជាច្រើនដាក់នៅសងខាងលើព្រះបល្ល័ង្ក ហើយនៅជិតខាងនោះ មានស្គរធំមួយ សំរាប់វាយប្រមូលឧបាសក ហើយនឹងលោកសង្ឃ កាលណាមានបុណ្យក្នុងវត្ត ។

នៅវេលាថ្ងៃសីល អស់ទាំងឧបាសកអ្នកកាន់សីលចូលទៅក្នុងវត្តស្តាប់លោកសូត្រធម៌ ។

## ៣៣._ ចៅកេតបំរើលោកគ្រូ

រាល់ព្រឹក ចៅកេតភ្ញាក់ពីព្រលឹម ទៅដងទឹកដាក់ពាង ហើយដងទឹកប្រគេនលោកគ្រូវាលុបព្រះភ័ក្ត្រ រួចចៅកេតបោសសំអាត លើកុដិ ក្រោមកុដិ រួចហើយ វាយកបាត្រនឹងបានស្រាក់មក ជូតឲ្យស្អាត ហើយដល់លោកគ្រូនិមន្តទៅបិណ្ឌបាត ចៅកេតយួរបានស្រាក់ដើរតាមលោកទៅ ។ អ្នកស្រុកប្រគេនសម្លត្រី - សាច់ ហើយនឹងផ្លែឈើ ចៅកេតកាន់យ៉ាងល្អ មិនឲ្យធ្លាក់កំពប់ឡើយ ។ លុះមកដល់កុដិហើយ ចៅកេតរៀបកន្លែងប្រគេនលោកគ្រូគង់ ហើយលើកបង្ហាន់ប្រគេន ព្រមទាំងផ្តិលទឹក នឹងសំពត់ជូតព្រះហស្តផង ។ លោកគ្រូឆាន់រួចហើយ ទើបចៅកេតជញ្ជូនយកអាហារដែលសល់នោះមកបរិភោគ ។ លុះចៅកេតស៊ីបាយហើយ វាមកអង្គុយជិតលោកគ្រូ បំរើតាមត្រូវការ ។

ពាក្យពន្យល់ : លុបព្រះភ័ក្ត្រ = ពាក្យសម្រាប់និយាយនឹងលោកសង្ឃ ឬនឹងស្ដេច ប្រែថាលាងមុខលុបមុខ ។ បាត្រ = ប្រដាប់រាងមូលរបស់លោកសង្ឃ សម្រាប់ដាក់បាយ ។ ប្រគេន = ប្រែថា ឲ្យ ។ បង្ហាន់ = គឺអាហារចំណីលោកសង្ឃ ។

អក្សរផ្ចង់ : ចៅកេតដងទឹកប្រគេនលោកគ្រូ ។

ព្រលឹងខ្មែរ

# ភាគបន្ថែម

(សម្រាប់គ្រូ)

## សន្តានពាក្យ

ដែលហៅថា *សន្តានពាក្យ* គឺក្រុមពាក្យចេញមកអំពីពាក្យដើមតែមួយ ប៉ុន្តែបានសេចក្តីផ្សេងពីគ្នា ឧបមាដូចពាក្យ *ផ្សើម សន្សើម* ជាសន្តានពាក្យចេញមកអំពីពាក្យ *សើម* ។ *អន្រែក សន្រែក* ជាសន្តានពាក្យចេញមកអំពីពាក្យ *រែក* ។

*

* *

## បទដើម (បុព្វបទ)

ដែលហៅថា *បទដើម* គឺព្យាង្គដើមផ្សំនឹងពាក្យដើមមួយ ឬ និងសំដីក្លាយពីពាក្យដើមមួយ កើតបានជាពាក្យថ្មីមួយទៀតពីរព្យាង្គ ឧបមាដូចក្នុងពាក្យ *បង្ហូរ* (បទដើម *បង* ផ្សំនឹងពាក្យដើម *ហូរ* ។

*បំពៅ* (បទដើម *បំ* ផ្សំនឹងពាក្យដើម *ពៅ*) ។ *កំណាត់* បទដើម *កំ* ផ្សំនឹង *ណាត់* សំដីក្លាយពីពាក្យដើម *កាត់* ។

*

* *

## កិរិយាសព្ទកើតពីកិរិយាសព្ទ ឬពីគុណនាមខ្លះ ដោយបទដើម បង បញ បណ បន បំ ៗ

មានកិរិយាសព្ទជាច្រើន ហើយនឹងគុណនាមខ្លះ យកបទដើម បង បញ បណ បន បំ កើតបានជាកិរិយាសព្ទថ្មីមួយទៀត ហើយបានក្នុងសេចក្ដីថា «ធ្វើឲ្យ» ។

១១.—បើកាលណាកិរិយាសព្ទ ឬគុណនាមដើមកើតដោយព្យញ្ជនៈ ក្នុងវគ្គ ក (គឺ ក ខ គ ឃ ង) ឬក្រៅវគ្គ (គឺ យ រ ល វ ស ហ) នោះ ប ទៅជាធាតុផ្ដើម បង ៗ ឧបមាដូចក្នុងពាក្យ ៖

| | | | | |
|---|---|---|---|---|
| បង្កើត | បទដើម ឬព្យាង្គដើម | បង | ពាក្យដើម | កើត |
| បង្ខំ | " | | " | ខំ |
| បង្រៀន | " | | " | រៀន |
| បង្ហូរ | " | | " | ហូរ |
| បង្ហាត់ | " | | " | ហាត់ |
| បង្ហើរ | " | | " | ហើរ |
| បង្វិល | " | | " | វិល |

ៗ ល ៗ

១២.—បើកាលណាកិរិយាសព្ទ ឬគុណនាមដើមកើតដោយអក្សរក្នុងវគ្គ ច (គឺ ច ឆ ជ ឈ ញ) នោះ ប ទៅជាបទដើម បញ ៗ ឧបមាដូចក្នុងពាក្យ ៖

| | | | | |
|---|---|---|---|---|
| បញ្ចេះ | បទដើម ឬ ព្យាង្គដើម | បញ | ពាក្យដើម | ចេះ |
| បញ្ចូល | " | | " | ចូល |
| បញ្ឆោត | " | | " | ឆោត |
| បញ្ជិះ | " | | " | ជិះ |
| បញ្ជោរ | " | | " | ជោរ |
| បញ្ឈប់ | " | | " | ឈប់ |
| បញ្ឈរ | " | | " | ឈរ |

។ល។

១៣.— បើកាលណាកិរិយាសព្ទ ឬ គុណនាមដើមកើតជាព្យញ្ជនៈក្នុងវគ្គ ដ (គឺ ដ ឋ ឌ ឍ ណ) នោះ ប ទៅជាធាតុដើម បណ ឬទៅជា ប្រ ឬ ផ ក៏មាន។

ឧបមាដូចក្នុងពាក្យ :

| | | | | |
|---|---|---|---|---|
| បណ្ដើរ | បទដើម ឬ ព្យាង្គដើម | បណ | ពាក្យដើម | ដើរ |
| បណ្ដុះ | " | | " | ដុះ |
| បណ្ដាច់ | " | | " | ដាច់ |
| ប្រដូច | បទដើម ឬ ព្យាង្គដើម | ប្រ | " | ដូច |
| ប្រដល់ | " | | " | ដល់ |
| ផ្ដួល | បទដើម ឬ ព្យាង្គដើម | ផ | " | ដួល |
| ផ្ដេក | " | | " | ដេក |

។ល។

១៦.— បើកាលណាកិរិយាសព្ទ ឬ គុណនាមដើមកើតដោយព្យញ្ជនៈក្នុងវគ្គ ត (គឺ ត ថ ទ ធ ន) នោះ ប ទៅជាធាតុផ្តើម បន ឧបមាដូចក្នុងពាក្យ:

| | | | |
|---|---|---|---|
| បន្ត | បទដើម ឬ ព្យាង្គដើម បន | ពាក្យដើម | ត |
| បន្តួប | " | " | តួប |
| បន្ទុំ | " | " | ទុំ |
| បន្ថយ | " | " | ថយ |
| បន្ថែម | " | " | ថែម |
| បន្ធំ | " | " | ធំ |

។ល។

១៧.— បើកាលណាកិរិយាសព្ទ ឬ គុណនាមដើមកើតដោយអក្សរក្នុងវគ្គ ប (គឺ ប ផ ព ភ ម) នោះ ប ទៅជាធាតុផ្តើម បំ ឧបមាដូចក្នុងពាក្យ:

| | | | |
|---|---|---|---|
| បំបៅ | បទដើម ឬ ព្យាង្គដើម បំ | ពាក្យដើម | បៅ |
| បំបែក | " | " | បែក |
| បំបាត់ | " | " | បាត់ |
| បំពាក់ | " | " | ពាក់ |
| បំភ្លឺ | " | " | ភ្លឺ |
| បំភ័យ | " | " | ភ័យ |

។ល។

*កិរិយាសព្ទកើតពីគុណនាម ឬពីកិរិយាសព្ទដូចគ្នាដោយដាក់ផ្តើម ស្រៈ អំ (ំ) ។*

តាមធម្មតា បើកាលណាគុណនាម ឬកិរិយាសព្ទណាមួយកើតដោយពួក *អក្សរគ្រាត់* (គឺផ្ញើជើង *រ*) ឬដោយពួកព្យញ្ជនៈក្រៅវគ្គផ្ញើជើង ហើយបើផ្លាស់យកស្រៈ *អំ* (ំ) មកផ្សំនឹងព្យញ្ជនៈដែលបង្កើតគុណនាម ឬកិរិយាសព្ទដើមនេះវិញ នោះកើតបានទៅជាកិរិយាសព្ទថ្មីមួយរូបទៀតមានពីរព្យាង្គ បានក្នុងសេចក្តីថា "ធ្វើឲ្យ" ឯជើងបានមកជាព្យាង្គទី ២ នាំយកទាំងស្រៈនឹងអក្សរប្រកបមកផង ។

ឯក្នុងពួកផ្ញើជើងឯទៀតក៏ដូចគ្នា ប៉ុន្តែព្យាង្គដើមកិរិយាសព្ទថ្មី យកព្យញ្ជនៈគូបន្ទាប់ខាងដើមក្នុងវគ្គ (*សិថិល*[១]) តាំង ។

ឧបមាដូចក្នុងពាក្យ :

| | | | | |
|---|---|---|---|---|
| *គំរប់ = គម្រប់* | បទដើម ឬ ព្យាង្គដើម | *គំ* | ពាក្យដើម *គ្រប់* | (គុណនាម) |
| *សំរួច = សម្រួច* | " | *សំ* | " *ស្រួច* | " |
| *សំរេច = សម្រេច* | " | " | " *ស្រេច* | " |
| *តំរឹម = តម្រឹម ឬ ដំរឹម = ដម្រឹម* | " | *តំ* ឬ *ដំ*[២] | " *ត្រឹម* | " |

(១) *សិថិល* គឺព្យញ្ជនៈសម្លេងស្រាលដូចជា *ក គ ច ជ* ។ល។

*ធនិត* គឺព្យញ្ជនៈសម្លេងខ្លាំង កើតអំពីសម្លេងសិថិលផ្សំនឹងសម្លេង *ហ* ដូចជា ខ *ឃ* ឆ *ឈ* ។ល។ (ក + ហ = ខ, គ + ហ = ឃ) ។

(២) ឮល់ ត ជួនណាដូលទៅជា *ដ* ។

| សំអាត | បទដើម ឬ ព្យាង្គដើម | សំ | ពាក្យផ្ដើម | ស្អាត | (គុណនាម) |
|---|---|---|---|---|---|
| តំរង់ = តម្រង់ ឬ ដំរង់ = ដម្រង់ | | " | " | ត្រង់ | " |
| តំរូវ = តម្រូវ ឬ ដំរូវ = ដម្រូវ | | " | " | ត្រូវ | " |
| សំរើប = សម្រើប | " | " | " | ស្រើប | " |
| សំដែង = សម្ដែង | " | " | " | ស្ដែង | " |
| សំរាល = សម្រាល | " | " | " | ស្រាល | " |
| លំអ | " | លំ | " | ល្អ | " |
| លំអិត | " | " | " | ល្អិត | " |
| ដំរះ = ដម្រះ | " | ដំ | " | ជ្រះ | " |
| ដំរុះ = ដម្រុះ | " | | " | ជ្រុះ | (កិរិយាសព្ទ) |
| ទំលាក់ = ទម្លាក់ | " | ទំ | " | ធ្លាក់ | " |

។ល។

## នាមកើតពីកិរិយាសព្ទដោយធាតុផ្ដើមស្រៈ អំ [១]

១១.– តាមធម្មតា បើកាលណាកិរិយាសព្ទកើតដោយព្យញ្ជនៈ សិថិល ហើយបើផ្លាស់យកស្រៈ អំ [១] មកផ្សំនឹងព្យញ្ជនៈនេះវិញ នោះកើតបានទៅជានាមពីរព្យាង្គ ស្រៈដើមនឹងអក្សរប្រកបរបស់កិរិយាសព្ទ ធិកមកនៅឯព្យាង្គក្រោយរបស់នាមនេះវិញ ឯព្យាង្គក្រោយនេះតាំងឡើងនឹងអក្សរ ណ ឬ ន តាមដោយព្យញ្ជនៈដែលបង្កើតកិរិយាសព្ទនោះជា អឃោសៈ ឬ ឃោសៈ ។

ឧបមាខ្លួបក្នុងពាក្យ :

| កំណាត់ | បទដើម ឬ ព្យាង្គដើម | កំ | ពាក្យដើម | កាត់ |
|---|---|---|---|---|
| កំណត់ | " | " | " | កត់ |
| ចំណេះ | " | ចំ | " | ចេះ |
| ចំណុះ | " | " | " | ចុះ |
| ចំណែក | " | " | " | ចែក |
| ដំណាំ | " | ដំ | " | ដាំ |
| ដំណើរ | " | " | " | ដើរ |
| ដំណេក | " | " | " | ដេក |
| សំណូក | " | សំ | " | សូក |
| សំណែន | " | " | " | សែន |
| សំណើច | " | " | " | សើច |
| គំនិត | " | គំ | " | គិត |
| គំនូរ | " | " | " | គូរ |
| ជំនូន | " | ជំ | " | ជូន |
| កំណល់ | " | កំ | " | កល់ |

| | | | | |
|---|---|---|---|---|
| ជំនួញ | បទដើម ឬ ព្យាង្គដើម | ជំ | ពាក្យដើម | ជួញ |
| ចំឡើយ = ចម្លើយ | „ | ចំ | „ | ឆ្លើយ |
| ជំលោះ = ជម្លោះ | „ | ជំ | „ | ឈ្លោះ |
| ទំនិញ | „ | ទំ | „ | ទិញ |
| ជំនួស | „ | ជំ | „ | ជួស |

។ល។

១២ — តាមធម្មតា បើកាលណាកិរិយាសព្ទ ឬ គុណនាមកើតដោយពួកអក្សរ *អក្សរត្រាត់* (គឺផ្ញើជើង ្រ) ឬដោយពួកព្យញ្ជនៈក្រៅវគ្គផ្ញើជើង នោះជើងនេះកើតបានទៅជាព្យាង្គក្រោយរបស់នាម នាំយកទាំងស្រៈនឹងអក្សរប្រកបមកផង ឯព្យាង្គដើមយកព្យញ្ជនៈរបស់កិរិយាសព្ទ ឬ គុណនាមនោះឯដែលផ្សំនឹងស្រៈ *អំ* ( ំ ) ឡើង ។

ឯក្នុងពួកផ្ញើជើងឯទៀតក៏ដូចគ្នា ប៉ុន្តែព្យាង្គដើមរបស់នាមកើតថ្មីនេះ យកព្យញ្ជនៈគួបន្ទាប់ខាងដើមក្នុងវគ្គ ( *សិថិល* ) តាំង ។

ឧបមាដូចក្នុងពាក្យ :

| | | | | |
|---|---|---|---|---|
| សំរែក = សម្រែក | បទដើម ឬ ព្យាង្គដើម | សំ | ពាក្យដើម | ស្រែក |
| សំរេក = សម្រេក | „ | សំ | „ | ស្រេក |
| ចំរូត = ចម្រូត | „ | ចំ | „ | ច្រូត |
| កំរាស់ = កម្រាស់ | „ | កំ | „ | ក្រាស់ |
| កំរាល = កម្រាល | „ | កំ | „ | ក្រាល |

| | | | | |
|---|---|---|---|---|
| សំដី | បទដើម ឬ ព្យាង្គដើម | សំ | ពាក្យដើម | ស្តី |
| កំពស់ = កម្ពស់ | " | កំ | " | ខ្ពស់ |
| បំប៉ាំង = បម្បាំង | " | បំ | " | បាំង |

។ ល ។

## នាមមួយព្យាង្គកើតពីកិរិយាសព្ទមួយព្យាង្គ

មានកិរិយាសព្ទជាច្រើនដែលកើតដោយព្យញ្ជនៈ *សិថិល* ឲ្យបានទៅជានាម យកព្យញ្ជនៈតួបន្ទាប់ក្នុងវគ្គ ( *ធនិត* ) ហើយនឹងជើង ន ផ្ញើមកជំនួសព្យញ្ជនៈដែលបង្កើតកិរិយា-សព្ទនោះវិញ ឯស្រៈនឹងអក្សរប្រកបនៅដូចដែល ។

ឯកិរិយាសព្ទដែលកើតដោយអក្សរក្រៅវគ្គក៏ដូចគ្នា ប៉ុន្តែយកព្យញ្ជនៈដដែល ។

ឧបមាដូចក្នុងពាក្យ :

| | | | | | |
|---|---|---|---|---|---|
| ខ្នើយ | មកពីកិរិយាសព្ទ | កើយ | ផ្នោល | មកពីកិរិយាសព្ទ | ដោល |
| ខ្នុប | " | កុប | ផ្នត់ | " | បត់ |
| ខ្នើត | " | កើត | ផ្នែក | " | បែក |
| ឃ្នាប | " | គាប | ស្នប់ | " | សប់ |
| ឈ្នាន់ | " | ជាន់ | ស្នែង | " | សែង |
| ឈ្នួត | " | ជួត | | | |

។ ល ។

# សារបាញរឿង

## ភាគទី ១


ទំព័រ

១ — ខ្យល់ស្រះ អ . . . . . . . . . . . . . . . . . . ២
២ — ខ្យល់ស្រះ អ៊ . . . . . . . . . . . . . . . . . . ៤
៣ — ព្យញ្ជនៈ ក ផ្សំនឹងស្រះ . . . . . . . . . . . . . . . ៦
៤ — ព្យញ្ជនៈ គ ផ្សំនឹងស្រះ . . . . . . . . . . . . . . . ៧
៥ — ព្យញ្ជនៈ ខ ឃ ង ផ្សំនឹងស្រះ . . . . . . . . . . . . . ៨
សារឡើងវិញ . . . . . . . . . . . . . . . . ១០
៦ — ព្យញ្ជនៈវគ្គទី ២ : ច ឆ ជ ឈ ញ ផ្សំនឹងស្រ. . . . . . . . . ១២
៧ ព្យញ្ជនៈវគ្គទី ៣: ដ ឋ ឌ ឍ ណ ផ្សំនឹងស្រះ . . . . . . . . ១៤
៨ — ព្យញ្ជនៈវគ្គទី ៤: ត ថ ទ ធ ន ផ្សំនឹងស្រះ . . . . . . . . . ១៦
សារឡើងវិញ . . . . . . . . . . . . . . . . . ១៨
៩ — ព្យញ្ជនៈវគ្គទី ៥ : ប ផ ព ភ ម ផ្សំនឹងស្រះ . . . . . . . . . ១៩
១០ — យ រ ល វ ផ្សំនឹងស្រះ . . . . . . . . . . . . . . . . ២២
១១ — ស ហ ឡ ផ្សំនឹងស្រះ . . . . . . . . . . . . . . . . ២៤
១២ — សម្មាប់ . . . . . . . . . . . . . . . . . . . . ២៦
សារឡើងវិញ . . . . . . . . . . . . . . . . . . ២៩
១៣ — អក្សរគំរប់ក្នុងភាសា: ឥ ឦ ឧ ឫ ឬ ឭ ឮ ឯ ឱ . . . . . . ៣០
១៤ — ប្រកបពាក្យនឹង ក . . . . . . . . . . . . . . . . ៣១
១៥ — ប្រកបពាក្យនឹង ច . . . . . . . . . . . . . . . . ៣៣
១៦ — ប្រកបពាក្យនឹង ត . . . . . . . . . . . . . . . . ៣៤
១៧ — ប្រកបពាក្យនឹង ប . . . . . . . . . . . . . . . . ៣៦

ទំព័រ


១៨ — ប្រកបពាក្យនឹង ខ . . . . . . . . . . . . . . . . ៣៨

១៩ — ប្រកបពាក្យនឹង ង នឹង ញ . . . . . . . . . . . . ៤០

២០ — ប្រកបពាក្យនឹង ម យ រ . . . . . . . . . . . . . ៤២

២១ — ប្រកបពាក្យនឹង ល វ ស . . . . . . . . . . . . . ៤៤

២២ — សញ្ញាសង្កត់ . . . . . . . . . . . . . . . . . ៤៦

២៣ — ខ្យល់ អាំង អាំង អោះ អោះ . . . . . . . . . . . ៤៨

សរុបនិទ្ទេស . . . . . . . . . . . . . . . . . ៥០

ពាក្យដាក់ជាក្រុមតាមខ្យល់សំនី . . . . . . . . . . . ៥២

២៤ — ជើងព្យញ្ជនៈ គ្រវាត់ . . . . . . . . . . . . . . ៦០

២៥ — ផ្ញើជើងនឹង ក ខ គ ឃ . . . . . . . . . . . . ៦៣

២៦ — ផ្ញើជើងនឹង ឆ ជ ឈ ឈ ត ថ ទ ធ . . . . . ៦៦

២៧ — ផ្ញើជើងនឹង ប ផ ព ភ ម ល ស ហ . . . . . ៦៨

សរុបនិទ្ទេស . . . . . . . . . . . . . . . . . ៧២

៤៨ — ពាក្យពីរព្យាង្គ - សរសេរគ្រួតព្យាង្គ . . . . . . . . ៧៣

២៩ — សញ្ញាផ្សេងៗ សំរាប់ប្រើក្នុងពាក្យខ្លះ ហើយនឹងអក្សរលើសពីប្រកប . ៧៩

## ភាគទី ២


| | | ទំព័រ |
|---|---|---|
| ១ – | ខ្ញុំទៅសាលារៀន | ៨២ |
| ២ – | រៀនមើលសៀវភៅ | ៨៣ |
| ៣ – | ប្រដាប់ប្រដារបស់កូនសិស្ស | ៨៤ |
| ៤ – | សាលារៀននៅភូមិខ្ញុំ | ៨៦ |
| ៥ – | កូនសិស្សល្អ | ៨៧ |
| ៦ – | កូនសិស្សអាក្រក់ | ៨៨ |
| ៧ – | កិច្ចដែលត្រូវប្រណិប័តន៍គ្រូ | ៨៩ |
| ៨ – | ខ្លួនមនុស្ស | ៩០ |
| ៩ – | ត្រូវសំអាតខ្លួនជានិច្ច | ៩២ |
| ១០ – | ត្រូវប្រយ័ត្ននឹងរោគ | ៩៣ |
| ១១ – | ក្រុមញាតិចៅកេត | ៩៥ |
| ១២ – | បងប្អូនចៅកេត | ៩៧ |
| ១៣ – | ស្រឡាញ់បងប្អូន | ៩៩ |
| ១៤ – | កំណើអាហារខ្មែរ | ១០១ |
| ១៥ – | ចិនស៊ីបាយ | ១០២ |
| ១៦ – | សំលៀកបំពាក់ | ១០៣ |
| ១៧ – | សំលៀកបំពាក់ (ត) | ១០៤ |
| ១៨ – | អំពីលំនៅ - ផ្ទះខ្មែរ | ១០៦ |
| ១៩ – | ភូមិខ្ញុំ | ១០៨ |
| ២០ – | ផ្សារនៅភូមិខ្ញុំ | ១០៩ |
| ២១ – | ការអ្នកធ្វើស្រែ | ១១១ |

ទំព័រ

២២ — ការអ្នកធ្វើស្រែ (ត) . . . . . . . . . . . . . . . . . . ១[illegible]
២៣ — ស្រូវ . . . . . . . . . . . . . . . . . . . . . ១១៤
២៤ — អំពីដំណាំ . . . . . . . . . . . . . . . . . . . ១១៦
២៥ — សត្វស្រុក . . . . . . . . . . . . . . . . . . . ១១៧
២៦ — មេទន្លេញ (ស្រង់ពីច្បាប់ក្រម) . . . . . . . . . . . . ១១៩
២៧ — ទំនុកច្រៀង (សារិកាកែវ) . . . . . . . . . . . . . ១២០
២៨ — ប្រដាប់ដឹកនាំអីវ៉ាន់ . . . . . . . . . . . . . . . . ១២១
២៩ — ក្នុងវង្សត្រកូលមួយ ៗ ធ្វើការទាំងអស់គ្នា . . . . . . . . ១២២
៣០ — ពេលវេលា . . . . . . . . . . . . . . . . . . . ១២៣
៣១ — យប់ អាទិត្យ ខែ ឆ្នាំ . . . . . . . . . . . . . . . ១២៤
៣២ — វិត្ត . . . . . . . . . . . . . . . . . . . . . ១២៦
៣៣ — ចៅកេតបំរើលោកគ្រូភិ . . . . . . . . . . . . . . . . ១២៧

## ភាគបន្ថែម

សវណ្ណានពាក្យ · ធាតុផ្តើមពាក្យ . . . . . . . . . . . ១៣០

IMPRIMERIE HENRY

មានលក់នៅបណ្ណាគារ ហង្ស-រី ភ្នំពេញ

និងគ្រប់បណ្ណាគារ ក្នុងកម្ពុជរដ្ឋ

AUTORISÉ PAR
Ministère Instruction Publique
Contrat enregistré ... 3.40
... 000 ex